# ដំណើរការរៀបចំដីកាស្តីពីការគ្រប់គ្រងកាកសំណល់រឹងក្រុងបាត់ដំបង

## ករណីតាក់តែងសេចក្តីព្រាងដីកា
## តាមបែបការចូលរួមនៅថ្នាក់ក្រុង-ស្រុក



COMPED

Konrad Adenauer Stiftung

LOTUS CONSULTING

សេរីភាព យុត្តិធម៌ និងសាមគ្គី ជាគោលការណ៍ក្នុងការកំណត់ សកម្មភាពរបស់មូលនិធិ ខុនរ៉ាដ អាដិន ណៅអ៊ែរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) គឺជាមូលនិធិនយោបាយមួយ ដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយគណបក្សសហភាពប្រជាធិបតេយ្យគ្រឹស្តសាសនិក (Christian Democratic Union) របស់ប្រទេសអាល្លឺម៉ង់។ លោក ខុនរ៉ាដ អាដិនណៅអ៊ែរ (១៨៧៦-១៩៧៦) គឺជាសហស្ថាបនិកនៃគណបក្ស CDU និងជាអធិការបតីដំបូងគេបង្អស់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានបង្រួបបង្រួមពួកសង្គមគ្រឹស្តនិយម ពួកអភិរក្សនិយម និងពួកសេរីនិយមទាំងឡាយ។ កិត្តិនាមរបស់លោក មានន័យដូចគ្នាទៅនឹងការកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ការយល់ស្របគ្នាលើគោលនយោបាយការបរទេសទៅនឹងគុណតម្លៃនៃសហគមមហាសមុទ្រអាត្លង់ទិក ចក្ខុវិស័យនៃការបង្រួបបង្រួមអឺរ៉ុប និងការតម្រង់ទិសឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសង្គម។ កេរ្តិ៍ដំណែលបញ្ញារបស់គាត់ គឺជាមូលដ្ឋាននៃគោលបំណង និងកាតព្វកិច្ចរបស់យើង។ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប និងអន្តរជាតិ យើងធ្វើការដើម្បីអោយមនុស្សអាចរស់នៅបានដោយកំណត់សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ខ្លួន។ ការងាររបស់យើងចូលរួមចំណែកជួយប្រទេសអាល្លឺម៉ង់ ក្នុងការបំពេញទំនួលខុសត្រូវរបស់ខ្លួនដែលកំពុងកើនឡើងនៅទូទាំងពិភពលោក។

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ បានចាប់ផ្តើមដំណើរការនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៤ មកដោយបានធ្វើការ យ៉ាងស្វិតស្វាញក្នុងការជួយគាំទ្រប្រជាជនកម្ពុជា ពង្រឹងលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្ស។ ដូច្នេះហើយ យើងធ្វើការដោយឆ្ពោះទៅរកការបង្កើតនូវបរិបទមួយដែលអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ រាល់កម្មវិធីទាំងអស់ សុទ្ធតែត្រូវបានបង្កើតឡើង និង អនុវត្តដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយដៃគូនៅកម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា កំពុងបំពេញការងាររបស់ខ្លួនក្នុងវិស័យដូចជា៖ កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ការពង្រឹងគណបក្សនយោបាយ និងសភា កំណែទម្រង់ច្បាប់ ការអភិវឌ្ឍប្រព័ន្ធឃោសនា ការអប់រំ នយោបាយ និងសេដ្ឋកិច្ចទីផ្សារសង្គម ក៏ដូចជាការពិគ្រោះយោបល់ផ្នែកគោលនយោបាយការបរទេសផងដែរ។

© រក្សាសិទ្ធិ ២០១៧ ដោយ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា

**មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា**
ផ្ទះលេខ២០៤ ផ្លូវលេខ៤៦២ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ +៨៥៥ ២៣ ៩៦៦ ១៧៦
ទូរសារលេខ ៖ +៨៥៥ ២៣ ២១៣ ៣៦៣
អ៊ីម៉ែល ៖ Office.PhnomPenh@kas.de
គេហទំព័រ ៖ www.kas.de/kambodscha
ហ្វេសប៊ុក ៖ www.facebook.com/kaskambodscha

## សេចក្តីថ្លែងអំណរគុណ

គម្រោងនេះនឹងមិនអាចប្រព្រឹត្តទៅដោយជោគជ័យនោះទេ ប្រសិនបើគ្មានការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានា។ ក្នុងន័យនេះ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (KAS) ប្រចាំប្រទេសកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ (NLC) ដែលបានផ្តល់ធាតុចូលសំខាន់ៗ ក្នុងដំណើរការនៃការតាក់តែងសេចក្តីព្រាងដីកា និងការរៀបចំសិក្ខាសាលានានា។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ក៏សូមថ្លែងអំណរគុណចំពោះ អង្គការ COMPED ក្នុងការរៀបចំសិក្ខាសាលា កិច្ចប្រជុំនានា និងការសិក្សាបឋមមួយ ដែលជារបាយការណ៍យ៉ាងសំខាន់ ហើយក៏បានផ្តល់ជំនួយការមួយរូបដល់អ្នកជំនាញការអន្តរជាតិរបស់យើង។ ជាមួយគ្នានេះផងដែរ យើងក៏សូមថ្លែងអំណរគុណចំពោះ អ្នកជំនាញការអន្តរជាតិ គឺលោកបណ្ឌិត ជោហ្គិន ស្ទៅឌែល (Dr. Jürgen Stäudel) ឡូធឹសខនសាល់ធីង (Lotus Consulting) ដែលបានធ្វើការសម្របសម្រួលក្នុងដំណើរការតាក់តែងសេចក្តីព្រាងដីកានេះ តាំងពីដើមរហូតដល់ចប់ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់។ អ្នកជំនាញការអន្តរជាតិរូបនេះ មានការយល់ដឹងយ៉ាងស៊ីជម្រៅទៅលើវប្បធម៌ និងឥរិយាបថការងាររបស់ប្រជាពលរដ្ឋខ្មែរ។

ជាចុងក្រោយ យើងក៏សូមថ្លែងអំណរគុណដល់សាលាក្រុងបាត់ដំបង សម្រាប់កិច្ចសហប្រតិបត្តិការយ៉ាងរលូន និងប្រកបដោយវិជ្ជាជីវៈ។ សូមថ្លែងអំណរគុណជាពិសេសដល់ លោកអភិបាលនៃគណៈអភិបាលក្រុងបាត់ដំបង លោក សៀង ឯម វុនស៊ី និងក្រុមការងារនៃក្រុមប្រឹក្សាក្រុងបាត់ដំបងទាំងអស់ ក្រុមប្រឹក្សាចៅសង្កាត់ មេភូមិ និងមន្ត្រីរាជការស៊ីវិលទាំងអស់ ដែលតែងតែទទួលស្វាគមន៍ យ៉ាងកក់ក្តៅ និងដោយបើកចំហដល់ក្រុមការងារយើង ព្រមទាំងបានធ្វើឱ្យគម្រោងមួយនេះទទួលបានជោគជ័យ។ ពួកគាត់បានចូលរួមយ៉ាងពេញទំហឹង និងដោយសេចក្តីសោមនស្ស។ យើងមានសេចក្តីរីករាយខ្លាំងណាស់ ដែលបានធ្វើការងារជាមួយពួកគាត់ទាំងអស់គ្នា ហើយយើងនឹងរង់ចាំមើលពីអនាគតនៃទីក្រុងបាត់ដំបង ដែលមានសណ្តាប់ធ្នាប់ល្អ និងដែលពោរពេញដោយបរិស្ថានស្អាត។

**រ៉េណេ ហ្គ្រោដវ៉ូល**
តំណាងប្រចាំប្រទេស
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ ៣
**អក្សរកាត់** ........ ៦

**១ សេចក្តីផ្តើម - ការបង្កើតដីកា** ........ ៧
១.១ ដំណើរការដោយសង្ខេប អំពីវដ្តនៃកាកសំណល់ ........ ៩
១.២ ការគ្រប់គ្រងកាកសំណល់រឹងក្នុងក្រុងបាត់ដំបង ........ ១០

**២ ដំណើរការរៀបចំសេចក្តីព្រាងដីកាស្តីពីការគ្រប់គ្រងកាកសំណល់រឹងក្រុងបាត់ដំបង** ........ ១២
២.១ ការកំណត់ពីតម្រូវការដីកា ........ ១៣
២.២ ការតាត់តែងសេចក្តីព្រាងដីកា ........ ១៥
២.៣ ដំណើរការដាក់ស្នើដីកាសម្រាប់ពិនិត្យឡើងវិញ និងពិគ្រោះយោបល់ ........ ១៨

**៣ ចក្ខុវិស័យ - ជំហានបន្ទាប់** ........ ២០
៣.១ ការគ្រប់គ្រងកាកសំណល់រឹងក្នុងក្រុងបាត់ដំបង ........ ២១
៣.២ ការអនុវត្តដោយម៉ឺងម៉ាត់
វិធានការត្រជាក់ និងវិធានការក្តៅ (Sweet and Sour) ........ ២៧
៣.៣ យុទ្ធនាការលើកកម្ពស់ការយល់ដឹង ........ ២៧

**៤ សេចក្តីសន្និដ្ឋាន** ........ ២៩

**៥ ឯកសារយោង និងព័ត៌មានបន្ថែម** ........ ៣០

# អក្សរកាត់

**BTB**........................................បាត់ដំបង ក្រុងបាត់ដំបង

**Cintri**.....................................អ្នកផ្តល់សេវា និងអ្នកប្រតិបត្តិការទីលានចាក់សំរាមក្នុងតំបន់

**COMPED** ................................អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា

**GIS** ........................................ប្រព័ន្ធព័ត៌មានភូមិសាស្រ្ត

**KAS** .......................................មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

**Leap Lim** ...............................លៀប លីម អ្នកផ្តល់សេវាក្នុងតំបន់

**SWG**.......................................អនុក្រុមការងារ

**SWM**......................................ការគ្រប់គ្រងសំរាម សំណល់រឹង

**TWG** .......................................ក្រុមការងារបច្ចេកទេសការគ្រប់គ្រងសំរាម សំណល់រឹង

**WG**..........................................ក្រុមការងារ

# ១ សេចក្តីផ្តើម - ការបង្កើតដីកា

មុននឹងផ្តល់សេចក្តីលម្អិតនៃរបាយការណ៍នេះ ការសំខាន់ដែលយើងត្រូវយល់ថា កាកសំណល់រឹងមិនមែនជារបស់អ្វីដែលយើងត្រូវគេចចេញឡើយ។ សំណល់រឹង គឺជាសមាសភាពមួយ ដែលសង្គមនីមួយៗមិនអាចជៀសវាងបាន។ របៀបដែលយើងគ្រប់គ្រងសំណល់រឹងនេះទៀតសោត គឺជាការឆ្លុះបញ្ចាំងឲ្យឃើញពីគន្លឹះសំខាន់ៗ ដែលនាំទៅដល់ភាពជោគជ័យក្នុងការគ្រប់គ្រងភាគីពាក់ព័ន្ធ វិធីសាស្រ្ត និងបញ្ហាប្រឈមនានា។ នៅក្នុងសង្គមសម័យបច្ចុប្បន្នរបស់យើង សំណល់រឹងត្រូវបានគេចាត់ទុកថាជាធនធានដ៏មានតម្លៃ។

របាយការណ៍នេះ ផ្តល់នូវការយល់ដឹងយ៉ាងសំខាន់មួយអំពីវិធីសាស្រ្ត ដែលអាចធ្វើទៅបានទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង ប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងសំណល់រឹងនេះទៀតសោត គួរតែជាគំរូដ៏ល្អមួយក្នុងការលើកទឹកចិត្ត និងបំផុសគំនិតដល់បណ្តារដ្ឋបាលក្រុង ស្រុកដទៃទៀតឲ្យស្វែងរកដំណោះស្រាយលើបញ្ហាគ្រប់គ្រងសំណល់រឹងប្រកបដោយប្រសិទ្ធភាព ព្រមទាំងស្វែងរកវិធីសាស្រ្ត ក្នុងការផ្លាស់ប្តូរសំណល់រឹង ឲ្យទៅជាសមាសភាពមួយដែលមានប្រយោជន៍ដល់សង្គម និងស្វែងរកវិធីមួយជំហានៗក្នុងការប្រើប្រាស់និងគ្រប់គ្រងធនធានរបស់ទីក្រុងទំនើបមួយនេះជាជាងព្យាយាមបំបាត់កាកសំណល់ឲ្យតែផុតពីភ្នែក។

វាប្រាកដណាស់ថា សំណល់រឹងនៅក្នុងប្រទេសកម្ពុជានឹងមានការកើនឡើងនៅទូទាំងប្រទេសកម្ពុជា។ ដូច្នេះ ដរាបណារដ្ឋបាលក្រុងស្រុកទាំងឡាយនៅកម្ពុជា ផ្តើមចាត់វិធានការគ្រប់គ្រងសំណល់រឹងឲ្យបានល្អ កាន់តែឆាប់ នោះសុខភាពសាធារណៈរបស់ប្រជាពលរដ្ឋ និងគុណភាពបរិស្ថាននឹងកាន់តែប្រសើរឡើង ដែលជាផ្នែកសំខាន់មួយនៃគុណភាពរស់នៅដ៏ល្អនៅប្រទេសកម្ពុជា។

គោល បំណងរួមនៃគម្រោងមួយនេះ គឺជម្រុញដល់កិច្ចខិត ខំប្រឹងប្រែង របស់រដ្ឋបាលក្រុងបាត់ដំបង ក្នុងការតា ក់តែងសេចក្តីព្រាង និងផ្សព្វផ្សាយដីកា ស្តីពីការគ្រប់គ្រងកាកសំណល់រឹង។ គម្រោងនេះត្រូវបានអនុវត្តឡើង ក្នុងក្របខ័ណ្ឌលើកកម្ពស់ដំណើរការអនុវត្តវិមជ្ឈការនៅកម្ពុជា ដែលជាបាតុភូតដ៏ក្មេងខ្ចីមួយ។

ទោះ ជា យ៉ាងណាក៏ដោយ គ្រប់ភាគីអ្នកចូលរួមទាំងអស់ បានឯកភាពលើដំណើរការចូលរួមនេះថា គឺជាការតាក់តែងបាននូវច្បាប់ដ៏ល្អមួយ ដែលមានលក្ខណៈវិនិច្ឆ័យសាមញ្ញ ភាសាសាមញ្ញ ប្រកបដោយប្រសិទ្ធភាពច្បាស់លាស់ និងប្រសិទ្ធផល។ ច្បាប់បែបនេះ អាចធ្វើជាសេចក្តីណែនាំមួយដល់ការអភិវឌ្ឍទីប្រជុំជននាពេលអនាគត និងជាវិធីសាស្រ្តដែលប្រកបដោយនិរន្តរភាព។

យោងតាមនិយមន័យ ដីកាគឺជាបទបញ្ញត្តិមូលដ្ឋានមួយដែលចេញដោយរដ្ឋបាលក្រោមជាតិ (អាជ្ញាធរមូល-ដ្ឋាន) នៅក្នុងដែនវិសាលភាពរបស់ខ្លួន[១]។ ក្នុងន័យនេះ ដីកានេះ ជាបទបញ្ញត្តិមួយសម្រាប់ដោះស្រាយបញ្ហាថ្នាក់ក្រុង ស្រុកដោយផ្ទាល់។ ដូច្នេះហើយ វាជាឧបករណ៍មួយដ៏មានសារៈសំខាន់ សម្រាប់ដោះស្រាយបញ្ហា និងការផ្លាស់ប្តូរឥរិយាបទ ក៏ដូចជាការបង្កើតយុទ្ធសាស្រ្តដ៏ស៊ីជម្រៅនៅក្នុងទម្រង់ច្បាប់នានា។ ដីកាស្តីពីការគ្រប់គ្រងសំណល់រឹងរបស់ក្រុងបាត់ដំបង ត្រូវបានបង្កើតឡើងដោយផ្អែកលើអនុក្រឹត្យលេខ១១៣ ដែលបានដាក់ចេញនូវគោលបំណងក្នុងមាត្រា២ ដូចតទៅ៖

ក. ដើម្បីបង្កើត និងអភិរក្សក្រុងបាត់ដំបងឲ្យទៅជាទីក្រុងបៃតង
ខ. ដើម្បីលើកកម្ពស់ ថែរក្សាសុខភាព និងអនាម័យសាធារណៈ

១ យោង៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុងស្រុក និងខណ្ឌ

គ. ដើម្បីពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង នៅក្រុងបាត់ដំបង និងរក្សាខ្ទង់ចំណាយអោយនៅកម្រិតសមរម្យដែលអាចផ្គត់ផ្គង់បាន

ឃ. ដើម្បីកំណត់ និងពង្រឹងតួនាទីនិងភារកិច្ចរបស់រដ្ឋបាលក្រុងបាត់ដំបង និងស្ថាប័នពាក់ព័ន្ធ (សង្កាត់ និងការិយាល័យពាក់ព័ន្ធ) អោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង តាមបែបទំនើប (SWM) ដែលផ្អែកទៅលើគោលការណ៍ 3R ពោលគឺការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ

ង. ដើម្បីបង្កើនការចូលរួម និងកំណត់ទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋក្រុងបាត់ដំបង អោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងតាមបែបទំនើប(SWM)ដែលផ្អែកទៅលើគោលការណ៍ 3R ពោលគឺការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ

ច. ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការស្វែងយល់អំពីតួនាទីនៃប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងបែបទំនើប ក្នុងការថែរក្សាអោយបាននូវបរិស្ថានស្អាត និងមានសុខភាពល្អ

ឆ. ដើម្បីបង្កើនការផ្ដល់សេវាប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង ទៅដល់ប្រជាពលរដ្ឋទូទាំងក្រុងបាត់ដំបង។

ដើម្បីសម្រេចបាននូវគោលបំណងទាំងឡាយខាងលើ ចាំបាច់តម្រូវឲ្យមានការចូលរួមយ៉ាងជិតស្និទ្ធ ដោយបើកចំហ និងដោយមានតម្លាភាពពីពហុភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង តាមបែបទំនើប (SWM)។ នៅក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ក្នុងដំណើរការតាក់តែងសេចក្តីព្រាងដីកានេះរួមមាន៖ ការិយាល័យគ្រប់គ្រងសំរាមនិងសោភ័ណ្ឌភាពក្រុងបាត់ដំបង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត មន្ទីរបរិស្ថានខេត្ត ក្រុមប្រឹក្សាក្រុងនិងសង្កាត់ ប្រធានភូមិ គណៈអភិបាលក្រុង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ អ្នកជំនាញការអន្តរជាតិមកពីឡូធីស ខនសាល់ធីង (Lotus Consulting) និងក្រុមហ៊ុនផ្តល់សេវាមកពីស៊ីនទ្រីនិងលៀបលីម។

ភាគីពាក់ព័ន្ធទាំងនេះ បាននាំនាំមកជាមួយនូវបទពិសោធន៍ សមត្ថភាព ទស្សនៈ និងផលប្រយោជន៍ខុសៗពីគ្នា។ ក្នុងការបង្កើតដីកា ដែលដូចជាការសាងសង់ស្ពានឆ្លងប្រឡាយដ៏ជ្រៅ គឺជាវិធិសាស្ត្រនៃការចូលរួមមួយ ត្រូវបានគេយកមកប្រើប្រាស់។ របាយការណ៍ខាងក្រោមនេះ បានរំលេចឡើងនូវជំហានសំខាន់ៗ ក្នុងការតាក់តែងសេចក្តីព្រាងដីកានេះ និងផ្តល់ជាទស្សនវិស័យមួយ។

## ១.១ ដំណើរការដោយសង្ខេប អំពីវដ្តនៃកាកសំណល់



### ការបង្កើតសំណល់

ការបង្កើតកាកសំណល់ គឺសំដៅលើបរិមាណសំណល់ដែលបានកើតមកពីទីក្រុង ក្រុមសង្គមនានា ឬប្រទេសជាតិ។ វាបានសំដៅផងដែរទៅលើ សមាសភាពនៃប្រភេទកាកសំណល់សំខាន់ៗដូចជា៖ សំរាម កាកសំណល់រឹង កាកសំណល់បៃតង កាកសំណល់ដែលអាចកែឆ្នៃបាន កាកសំណល់សំពីងសំពោង កាកសំណល់គ្រោះថ្នាក់ និងកាកសំណល់ពីការដ្ឋាន។ ព័ត៌មានលំអិតអំពីបរិមាណ និងសមាសភាព គឺមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍយុទ្ធសាស្រ្តគ្រប់គ្រងកាកសំណល់គ្រប់ជ្រុងជ្រោយមួយ។ នគរូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ការផ្លាស់ប្តូរឥរិយាបថប្រើប្រាស់ ជារឿយៗនាំឲ្យមានការកើនឡើងនូវប្រភេទកាកសំណល់ពិសេសតាមតំបន់ជាក់លាក់ ដែលតម្រូវឲ្យមានដំណោះស្រាយជាក់លាក់ផងដែរ។



### ការស្តុក និងយកកាកសំណល់ចេញពីប្រភព

គេហដ្ឋាន មន្ទីរពេទ្យ ភោជនីយដ្ឋាន សាលារៀន ផ្សារ និងតំបន់ក្រុមហ៊ុនឯកជនបង្កើតប្រភេទ កាកសំណល់ផ្សេងៗគ្នា។ ប្រភេទកាកសំណល់នីមួយៗត្រូវការរបៀបគ្រប់គ្រងទុកដាក់ខុសៗពីគ្នា។ ឧទាហរណ៍ កាកសំណល់សរីរាង្គ និងកាកសំណល់បៃតងអាចយកទៅធ្វើជាជីកំប៉ុស្តបាន។ កំប៉ុង និងដបប្លាស្ទិកអាចយកមកកែឆ្នៃឡើងវិញបាន។ កាកសំណល់ថ្នាំពេទ្យអាចយកទៅដុតនៅក្នុងឡដុតសំរាមពិសេស។ ដើម្បីធានាបានថាចរន្តប្រភេទសំរាមនីមួយៗ ត្រូវបានគ្រប់គ្រងទុកដាក់ក្នុងកន្លែង និងតាមរបៀបត្រឹមត្រូវបំផុត។ យើងត្រូវតែបែងចែកសំរាមទាំងនោះ ទៅតាមប្រភេទរបស់វា និងប្រមូលដោយប្រុងប្រយ័ត្ន មិនអោយមានការលាយឡំគ្នារវាងប្រភេទកាកសំណល់ខុសគ្នា ឬការដឹកជញ្ជូនទៅកាន់កន្លែងខុសនោះទេ។



### ការប្រមូល និងការដឹកជញ្ជូន

វាមានវិធីច្រើនណាស់ក្នុងការប្រមូល សំរាមចេញពីប្រភពផលិត។ វិធីសាស្រ្តមួយ គឺការជ្រើសរើសក្រុមហ៊ុនឯកជនមួយ ជាអ្នកប្រមូលសំរាម សម្អាតកន្លែងស្តុកសំរាម ហើយដឹកជញ្ជូនសំរាមទៅតាមស្ថានីយ៍ផ្ទេរជាដើម។ តាមការសង្កេតបច្ចុប្បន្ន សំរាមនៅប្រទេសកម្ពុជា ត្រូវបានប្រមូលដោយប្រើប្រាស់ថង់ប្លាស្ទិក ឬកំផុងសំរាម។ លើលពីនេះទៅទៀត គេពុំទាន់បានញែកសំរាមនៅឡើយទេ ដែលជាហេតុបណ្តាលឲ្យខាតធនធានដែលមានតម្លៃ និងសក្តានុពលសេដ្ឋកិច្ចជាដើម។



### ការចោល ការកែច្នៃសំរាមឡើងវិញ

ប្រព័ន្ធគ្រប់គ្រងសំរាមដែលទំនើបបំផុត គឺជាប្រព័ន្ធដែលកែច្នៃសំរាមគ្រប់ប្រភេទឲ្យទៅជាថាមពល ផលិតផលថ្មី ឬធនធានផ្សេងៗទៀត។ នៅក្នុងកំឡុងប៉ុន្មានឆ្នាំនេះ ប្រព័ន្ធគ្រប់គ្រងសំរាមរឹងនៅកម្ពុជា ត្រូវបានគេអភិវឌ្ឍជាលំដាប់ ហើយសំរាមកាន់តែច្រើនបានស្ថិតនៅក្នុងប្រព័ន្ធដែលបានរៀបចំ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាដុតសំរាមដោយខុសច្បាប់ ការចោលសំរាមពាសវាលពាសកាល កំពុងតែបំផ្លាញសេដ្ឋកិច្ចបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាបានបាត់បង់ធនធានដ៏មានតម្លៃដូចជាសំរាមកែច្នៃ ដែលត្រូវបានដឹកជញ្ជូនទៅកាន់ប្រទេសជិតខាង ហើយត្រូវបានកែច្នៃនៅទីនោះ ជាជាងរក្សាទុកនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ ដំណោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយការបង្កើតបទបញ្ញត្តិនៅថ្នាក់មូលដ្ឋាន តាមរយៈការកំណត់យន្តការលើកកំពស់ឧស្សាហកម្មកែច្នៃសំរាមក្នុងស្រុក និងពង្រឹងការផ្តន្ទាទោស លើអំពើទាំងឡាយណាដែលរំលោភបំពានច្បាប់បរិស្ថាន ដែលជាវិធីមួយដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ស្តង់ដាគុណភាពនៃទីលានចាក់សំរាមក៏ចាំបាច់ត្រូវកែលម្អជាបន្ទាន់ផងដែរ។

## ១.២ ការគ្រប់គ្រងកាកសំណល់រឹងក្នុងក្រុងបាត់ដំបង

ក្រុងបាត់ដំបង គឺជាក្រុងធំបំផុតលំដាប់ទី២ក្នុងប្រទេសកម្ពុជា ដែលមានប្រជាជនសរុបចំនួន ១៥២.០៣២នាក់ និងផ្ទៃដី ១១៥,៤៤គ.ម$^{២}$។ កសិកម្ម គឺជាវិស័យសេដ្ឋកិច្ចចំបងរបស់ក្រុងបាត់ដំបង ដែលប្រមាណជា ៧៤% នៃផ្ទៃដីសរុប គឺជាផ្ទៃដីកសិកម្ម។

ជាមធ្យម ប្រជាជនក្នុងក្រុងបាត់ដំបងបង្កើតកាកសំណល់បានប្រមាណជា ១២៦តោន ក្នុងមួយថ្ងៃ។ ទាំងនេះ គឺរាប់បញ្ចូលទាំងកាកសំណល់ ដែលចេញពីគេហដ្ឋាន ស្ថាប័ន ក្រុមហ៊ុន ទីផ្សារ ទេសចរណ៍ និងសកម្មភាពកសិឧស្សាហកម្ម។ ស្រដៀងគ្នានឹងខេត្តផ្សេងៗទៀតនៅទូទាំងព្រះរាជាណាចក្រកម្ពុជាដែរ ក្រុងបាត់ដំបងបាននិងកំពុងតែមានការអភិវឌ្ឍសេដ្ឋកិច្ច ហើយក៏កំពុងតែប្រឈមនឹងការកើនឡើងនូវការប្រើប្រាស់ និងផលិតផលប្រើប្រាស់ ជាហេតុនាំអោយមានការផលិតសំរាមកាន់តែមានការកើនឡើងផងនៅឆ្នាំបន្តបន្ទាប់។

តាមការប៉ាន់ប្រមាណ ជាមធ្យមសំរាមប្រហែល ៨០តោន ត្រូវបានគេប្រមូលជារៀងរាល់ថ្ងៃ។ សំរាមទាំងនេះភាគច្រើនត្រូវបានគេប្រមូលពីលំនៅដ្ឋាន ក្រុមហ៊ុន និងផ្សារ ហើយយកទៅចាក់នៅទីលានសំរាមក្រុងបាត់ដំបង។ សំរាមប្រហែល ១៥តោន ក្នុងមួយថ្ងៃត្រូវបានប្រមូលដោយអ្នករើសអេតចាយ ហើយត្រូវបានកែច្នៃឡើងវិញ ដោយហាងអេតចាយ។ សំរាមដែលនៅសល់ប្រហែលជា ៣០តោនក្នុងមួយថ្ងៃផ្សេងទៀត មិនត្រូវបានគេប្រមូល ឬគ្រប់គ្រងឲ្យបានល្អនោះទេ។ នៅក្នុងក្រុងបាត់ដំបង មានក្រុមហ៊ុនប្រមូលសំរាមពីរ៖ ស៊ិនទ្រី (CINTRI) (ចំនួន៨សង្កាត់) និងក្រុមហ៊ុន លៀប លីម (Leap Lim) (ចំនួន២សង្កាត់)។

ជាលទ្ធផល ទីលានចាក់សំរាមក្នុងក្រុងបាត់ដំបង គឺជាកន្លែងចំបងសម្រាប់ចោលកាកសំណល់រឹងក្នុងក្រុងបាត់ដំបងទាំងមូល។ អង្គការ COMPED បានធ្វើការសិក្សាមួយចំនួន ហើយបានរកឃើញថាកាកសំណល់រឹងនៅទីលានចាក់សំរាមភាគច្រើន (ប្រមាណជា៧០%) គឺជាប្រភេទសំណល់សរីរាង្គ ហើយ ១៥-២០% ផ្សេងទៀតជាថង់ប្លាស្ទិក សល់ពីនេះគឺក្រដាស និងអំបែង។ ជាពិសេស សំណល់ដែលប្រមូលចេញពីផ្សារ មាន

សមាសភាគជាសំណល់សរីរាង្គច្រើន។




*ស្ថានភាពនៃការផលិត និងចោលសំណល់ក្នុងក្រុងបាត់ដំបង (រូបភាពផ្ទាល់ខ្លួន)*

## ២ ដំណើរការរៀបចំសេចក្តីព្រាងដីកាស្តីពី ការគ្រប់គ្រងកាកសំណល់រឹងក្រុងបាត់ដំបង

គម្រោងសាកល្បង ក្នុងការរៀបចំដីកាស្តីពីការគ្រប់គ្រងកាកសំណល់រឹងក្រុងបាត់ដំបង បានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០១៦ ហើយបញ្ចប់នៅខែមេសា ឆ្នាំ២០១៧។ ខាងក្រោមនេះ គឺជាជំហានដែលយើងបានអនុវត្តក្នុងការរៀបចំបង្កើតសេចក្តីព្រាងដីកា រហូតទទួលបានជោគជ័យ។ ដំណើរការទាំងមូលត្រូវបានសម្របសម្រួលដោយក្រុមសម្របសម្រួល ដែលមានសមាសភាពដូចជា៖ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (KAS) ឡូធឹសខនសាល់ធីង (Lotus Consulting) អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED)សម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំសង្កាត់ និងការិយាល័យគ្រប់គ្រងសំរាមនិងសោភ័ណ្ឌភាពទីក្រុងបាត់ដំបង។

**១. កំណត់តម្រូវការដីកា**
- ការសិក្សាបឋម
- ការបង្កើតក្រុមការងារបច្ចេកទេស
- ការបញ្ជាក់ក្រុមស្រាវជ្រាវបឋម

**២. សេចក្តីព្រាងដីកា**
- ការចាប់ផ្តើមបង្កើតសេចក្តីព្រាងដីកាក្នុងក្រុមការងារបច្ចេកទេស
- សិក្ខាសាលាពាក់កណ្តាលគម្រោង (Holding Mid-term workshop)
- ការកែសម្រួល និងបញ្ចប់សេចក្តីព្រាងដីកា

**៣. ដាក់ដីកាពិនិត្យឡើងវិញ និងពិគ្រោះយោបល់**
- បញ្ជូនសេចក្តីព្រាងដីកា ទៅកាន់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ដើម្បីពិនិត្យពិគ្រោះយោបល់

## ២.១ ការកំណត់ពីតម្រូវការដីកា

### ១. ការសិក្សាស្រាវជ្រាវបឋម[២]

ការសិក្សាបឋម ត្រូវបានធ្វើឡើងដោយអង្គការក្នុងស្រុកមួយឈ្មោះ COMPED ដែលមានបទពិសោធន៍ទាក់ទងនឹងវិស័យគ្រប់គ្រងសំណល់នៅប្រទេសកម្ពុជា អស់រយៈពេលជាង ១៥ឆ្នាំ។ ផ្នែកមួយនៃការសិក្សាបឋមនេះ គឺការចុះទៅដល់ទីលានចាក់សំរាមនៅក្រុងបាត់ដំបង កន្លែងរេតចាយ សាលាក្រុង ជួបក្រុមប្រឹក្សាសង្កាត់ និងការជួបប្រជុំជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីបញ្ហាប្រឈម តម្រូវការ និងស្ថានភាពបច្ចុប្បន្ន។ បញ្ហាមួយក្នុងចំណោមបញ្ហាចម្បងៗទាំងអស់ គឺការមិនចុះសម្រុងគ្នារវាងប្រជាពលរដ្ឋដែលមិនចង់បង់ថ្លៃខ្ពស់លើសេវាប្រមូលសំរាម និងក្រុមហ៊ុនប្រមូលសំរាម។

ប្រជាពលរដ្ឋបានបន្ទោស ក្រុមហ៊ុនផ្តល់សេវា ពីរឿងមិនប្រមូលសំរាមឲ្យបានទៀងទាត់។ ម៉្យាងវិញទៀត ការសិក្សាបឋមនេះ ក៏អាចជួយឲ្យយើងដឹងពីស្ថានភាពរបស់ក្រុមហ៊ុនផ្តល់សេវា បញ្ហាហិរញ្ញវត្ថុ ធនធានមនុស្ស និងបញ្ហាបច្ចេកទេសនានាផងដែរ។ លើសពីនេះទៅទៀត ការសិក្សាបឋមនេះទៀតសោត បានផ្តល់នូវទិដ្ឋភាពរួមទូទៅមួយ ស្តីពីទិដ្ឋភាពច្បាប់ ការបង្កើតសំណល់ជាក់លាក់ ក៏ដូចជាហានិភ័យនានា ដែលទាក់ទងទៅនឹងការអនុវត្តគម្រោងសាកល្បងនេះ។

> ការប្រាស្រ័យទាក់ទងដែលមានលក្ខណៈបើកចំហ និងស្មោះត្រង់គឺជាកិច្ចចាំបាច់មួយ ដើម្បីទទួលបាននូវការយល់ដឹងដ៏ជាក់ស្តែងអំពីស្ថានភាពទាំងមូល។ កិច្ចប្រជុំទៀងទាត់ ដែលមានការរៀបចំឡើងល្អ និងមានតម្លាភាព គឺមានសារៈសំខាន់ណាស់។ កិច្ចប្រជុំបែបនេះ ត្រូវផ្តោតទៅលើព័ត៌មានដែលអាចទុកចិត្តបាន និងមានការវិភាគទិន្នន័យជាក់ស្តែង។ ដៃគូពាក់ព័ន្ធទាំងអស់គួរតែចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះ។

### ២. ការបង្កើតក្រុមការងារ

មុននឹងគម្រោងនេះចាប់ផ្តើម សាលាក្រុងបាត់ដំបង ធ្លាប់បានបង្កើតក្រុមបច្ចេកទេសមួយ សម្រាប់គ្រប់គ្រងកាកសំណល់រឹងរួចទៅហើយ។ ក្រុមបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង បានផ្តល់មូលដ្ឋានដ៏ល្អសម្រាប់ការអនុវត្តគម្រោង។

ក្រុមការងារនេះត្រូវបានបង្កើតឡើងដោយ៖ សមាជិកនៃរដ្ឋបាលខេត្ត (នាយកដ្ឋានបរិស្ថាន និងនាយកដ្ឋានហិរញ្ញវត្ថុ) សមាជិកនៃក្រុមប្រឹក្សាក្រុង សមាជិកនៃគណៈកម្មាធិការកិច្ចការនារី និងគណៈកម្មាធិការបច្ចេកទេសកិច្ចការបរិស្ថាន អភិបាលក្រុង និងអ្នកតំណាង ការិយាល័យគ្រប់គ្រងសំរាម និងសោភ័ណ្ឌភាពទីក្រុងបាត់ដំបង និងអ្នកតំណាងសង្កាត់ ប្រធានភូមិ និងនាយកដ្ឋានក្រុងផ្សេងៗទៀត (សូមមើលខាងក្រោម)។

---

២ ចំណងជើងរបស់ការសិក្សាស្រាវជ្រាវបឋម៖ "ស្ថានភាពការគ្រប់គ្រងសំណល់ក្នុងក្រុងបាត់ដំបង" ដើម្បីគាំទ្រដល់ការអភិវឌ្ឍលក្ខន្តិកៈសំណល់សម្រាប់ក្រុងបាត់ដំបង។ អាចសួររកបាននៅមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរប្រចាំប្រទេសកម្ពុជា

ជាចុងក្រោយក្រុមបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង គឺជាគណៈកម្មាធិការចម្បងដែលទទួលខុសត្រូវក្នុងការធ្វើសេចក្តីព្រាងដីកា។ ដើម្បីធ្វើឲ្យការសរសេរខ្លឹមសាររបស់ដីកាកាន់តែមានប្រសិទ្ធភាព ក្រុមការងារបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង ត្រូវបានបែងចែកជាក្រុមតូចៗទៀត(មើលជំហានបន្ទាប់)។ ការងារចម្បងរបស់ក្រុមការងារបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង គឺការធ្វើសេចក្តីព្រាងដីកា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដែលនឹងបំរើផលប្រយោជន៍អោយប្រជាពលរដ្ឋក្រុងបាត់ដំបង កំណត់គោលបំណង តួនាទីភារកិច្ច និងជំហានបន្ទាប់សម្រាប់សកម្មភាពរយៈពេលខ្លី និងរយៈពេលវែង ក្នុងការគ្រប់គ្រងកាកសំណល់រឹងនៅទីក្រុងបាត់ដំបង។

## ៣. ការធ្វើអាយត្រឹមត្រូវនូវលទ្ធផលនៃការសិក្សាបឋម

ជារួមការពិភាក្សា និងសុពលភាពនៃបញ្ហាសំខាន់ៗ គឺជាជំហានបន្ទាប់។ ដើម្បីធ្វើដូច្នេះបាន **សិក្ខាសាលាបឋម** ត្រូវបានធ្វើឡើងនៅសាលសាលាក្រុងបាត់ដំបង។ ដើម្បីឲ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ទទួលបានអារម្មណ៍ថាខ្លួនជាម្ចាស់លើដីកា វិធីសាស្ត្រនៃការចូលរួមត្រូវបានយកមកប្រើប្រាស់។ ក្របខ័ណ្ឌស្ថាប័នលក្ខណៈសេដ្ឋកិច្ចនិងសង្គម ក៏ដូចជាតម្រូវការបច្ចេកទេសនៃការគ្រប់គ្រងសំណល់រឹងនៅក្រុងបាត់ដំបង ត្រូវបានភាគីពាក់ព័ន្ធទាំងអស់ យកមកពិភាក្សានៅក្នុងសកម្មភាពបន្ទាប់ដូចមានរៀបរាប់ខាងក្រោម៖

**សិក្ខាសាលាបឋមមានគោលបំណងដូចខាងក្រោម៖**

- ការណែនាំខ្លួនរបស់ភាគីពាក់ព័ន្ធទាំងអស់
- សេចក្តីផ្តើម និងការពិភាក្សាអំពីតម្រូវការដីកាថ្មី
- ស្ថានភាពទូទៅនៃកាកសំណល់ និងការអនុវត្តល្អៗក្នុងតំបន់
- សុពលភាពនៃបញ្ហាសំខាន់ៗដោយមានការចូលរួមពីភាគីពាក់ព័ន្ធ
- កំណត់ជំហានបន្ទាប់ និងក្រុមការងារបច្ចេកទេស

**អ្នកចូលរួមក្នុងសិក្ខាសាលាបឋម និងក្រុមការងារបច្ចេកទេសមានសមាសភាពដូចតទៅ៖**

- អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង
- អភិបាលរងខេត្តបាត់ដំបង
- ការិយាល័យរដ្ឋបាលខេត្ត
- មន្ទីរបរិស្ថានខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- មន្ទីរទេសចរណ៍ខេត្ត
- មន្ទីរសុខាភិបាល
- មន្ទីរអប់រំយុវជន និងកីឡា
- ការិយាល័យគ្រប់គ្រងសំរាម និងសោភ័ណ្ឌភាពក្រុងបាត់ដំបង
- សមាគមន៍ ក្រុមប្រឹក្សាខេត្ត ក្រុង
- ចៅសង្កាត់
- ក្រុមហ៊ុនឯកជន (ស៊ីនទ្រី និងលៀប លីម)
- សម្ព័ន្ធភាពជាតិឃុំសង្កាត់

- មូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា
- ឡូធីសខនសាល់ធីង (Lotus Consulting)
- អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED)



*រូបនេះបង្ហាញពីសកម្មភាពអ្នកចូលរួមកំពុងពិភាក្សារកដំណោះស្រាយបញ្ហាផ្សេងៗ ទាក់ទងទៅនឹងការគ្រប់គ្រងសំណល់រឹង។*



*រូបនេះបង្ហាញពីសកម្មភាពអ្នកចូលរួមកំពុងតែបន្ថែមគំនិតសំខាន់ៗទៅលើការងាររបស់ក្រុមមុន។*

## ២.២ ការតាក់តែងសេចក្តីព្រាងដីកា

ក្រោយពីកំណត់បញ្ហាសំខាន់ៗ តាមរយៈការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធទាំងឡាយ និងក្រោយពីកិច្ចពិភាក្សាអំពី យុទ្ធសាស្ត្រដោះស្រាយបញ្ហា ក្នុងពេលសិក្ខាសាលាបឋមរួចមក ក្រុមការងារបច្ចេកទេសបានចាប់ផ្តើមសរសេរសេចក្តីព្រាងដីកា ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

### ១. ការចាប់ផ្តើមបង្កើតសេចក្តីព្រាងដីកាក្នុងក្រុមការងារបច្ចេកទេស

ដោយសារតែសមាជិកនីមួយៗក្នុងក្រុមការងារបច្ចេកទេសមានបទពិសោធន៍ គំនិតយោបល់ និងការចំណាប់អារម្មណ៍ផ្សេងៗគ្នា ក្រុមការងារបច្ចេកទេសនេះ ត្រូវបានបែងចែកជាក្រុមតូចៗទៀត ដែលគេហៅថាអនុក្រុមការងារបច្ចេកទេស។ អនុក្រុមការងារបច្ចេកទេសនីមួយៗ ធ្វើការផ្តោតទៅលើផ្នែកមួយនៃខ្លឹមសារដីកា ហើយពិភាក្សាទៅរកដំណោះស្រាយលើបញ្ហាជាក់ស្តែងក្នុងសេណារីយ៉ូ។

**អនុក្រុមការងារបច្ចេកទេស១ - ទម្រង់ទូទៅ ការគ្រប់គ្រង ក្រុមប្រឹក្សាស្រុក (អ្នកជំនាញការបច្ចេកទេស)៖** *(ក្រុមហ៊ុនស៊ិនទ្រី ចៅសង្កាត់ឬអ្នកតំណាង ការិយាល័យគ្រប់គ្រងសំរាមនិងសោភ័ណ្ឌភាពទីក្រុង ក្រុមប្រឹក្សាក្រុងស្រុក ផ្សេងៗ)។*

- ទម្រង់ទូទៅនៃដីកា
- តម្រូវការតាមច្បាប់
- ការកែលម្អបច្ចេកទេស
- ការជំរុញការកែច្នៃកាកសំណល់
- ការប្រើប្រាស់ធនធានឡើងវិញ

- កាកសំណល់គ្រោះថ្នាក់
- កាកសំណល់ពីមន្ទីរពេទ្យ
- ជំហានបន្ទាប់ និងការអនុវត្ត

**អនុក្រុមការងារបច្ចេកទេស២ - ការកំណត់ថ្លៃសេវា និងសេវាកម្មប្រមូលប្រាក់**

*(បទបញ្ញា សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបរិស្ថាន ស៊ីនទ្រី លៀប លីម ការិយាល័យគ្រប់គ្រងរដ្ឋបាលនិងកាកសំណល់ តំណាងសង្កាត់)*

- ការកែលម្អប្រព័ន្ធប្រមូល និងដឹកជញ្ជូនកាកសំណល់
- ការកែលម្អប្រព័ន្ធប្រមូលសំរាមដែលយកចេញមកដាក់តាមដងផ្លូវ (curbside collection)
- ការរៀបចំប្រតិទិន ចំនួនដង ក្នុងការប្រមូលសំណល់
- ការវិភាគទៅលើតម្រូវការហិរញ្ញវត្ថុ
- ការកែលម្អបទបញ្ញា
- ការផ្តល់ហិរញ្ញប្បទានឡើងវិញ
- ការកែលម្អប្រព័ន្ធតម្លៃសេវា

**អនុក្រុមការងារបច្ចេកទេស៣ - ការលើកកម្ពស់ការយល់ដឹង**

*(អភិបាលរង ការិយាល័យរដ្ឋបាលក្រុងនិងគ្រប់គ្រងសំរាម តំណាងសង្កាត់ នាយកដ្ឋានបរិស្ថាន តំណាងរបស់គណៈកម្មាធិការកិច្ចការកុមារនិងកិច្ចការនារី ផ្សេងៗ)*

- ការកំណត់បញ្ហា
- ការធ្វើការសំណូមពរដើម្បីកែលម្អ
- ការលើកកម្ពស់ការយល់ដឹងពីសុខភាព អនាម័យទីប្រជុំជន និងបរិស្ថាន
- ការប្រាស្រ័យទាក់ទងជាមួយប្រជាជន
- ការអប់រំនៅតាមសាលារៀន វត្តអារាម និងសាកលវិទ្យាល័យ
- ជំរុញឆន្ទៈប្រជាជនអោយបង់ថ្លៃសេវា

**អនុក្រុមការងារបច្ចេកទេស៤ - ការបែងចែកសំរាម ការកែច្នៃសំរាម និងការគ្រប់គ្រងទីលានចាក់សំរាម**

*(ការិយាល័យរដ្ឋបាលក្រុងនិងគ្រប់គ្រងសំរាម តំណាងសង្កាត់ លៀប លីម សមាជិកក្រុមប្រឹក្សាសង្កាត់ ផ្សេងៗ)*

- ការដាក់លក្ខខណ្ឌពិសេសចំពោះអាជីវកម្ម ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ទ្រង់ទ្រាយធំ
- ការអនុវត្តប្រព័ន្ធនៃការបែងចែកសំរាម
- ការប្រមូលសំរាមតាមដងផ្លូវ និងប្រព័ន្ធវិមជ្ឈការនាំយកនៅតាមតំបន់ដាច់ស្រយាល
- ការបញ្ចូលវិស័យកែច្នៃសំរាមក្រៅផ្លូវការ (អ្នកប្រមូលសំរាម)
- បទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងទីលានចាក់សំរាម

## ២. សិក្ខាសាលានៅពាក់កណ្តាលគម្រោង

ដើម្បីពិនិត្យ តាមដាន និងវាយតម្លៃលើសមិទ្ធិផលការងាររបស់អនុក្រុមការងារបច្ចេកទេស គេបានរៀបចំឲ្យមានជាសិក្ខាសាលានៅពាក់កណ្តាលគម្រោងមួយ នៅក្នុងសាលាក្រុងបាត់ដំបង។ ក្របខ័ណ្ឌស្ថាប័នមូលដ្ឋាន (ថ្នាក់ក្រុង) លក្ខណៈសេដ្ឋកិច្ចនិងសង្គម ក៏ដូចជាលក្ខខណ្ឌបច្ចេកទេសនៃការគ្រប់គ្រងកាកសំណល់រឹង នៅ

ក្រុងបាត់ដំបង ត្រូវបានលើកយកមកពិភាក្សាយ៉ាងស្វិតស្វាញក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។

**គោលបំណងក្នុងការរៀបចំសិក្ខាសាលានៅពាក់កណ្តាលគម្រោងគឺដើម្បី៖**

- ពិភាក្សាអំពីការអនុវត្តដីកា
- វាយតម្លៃលើលទ្ធភាពជាក់ស្តែងក្នុងការអនុវត្តប្រព័ន្ធបែងចែកសំរាម និងការគ្រប់គ្រងទីលានចាក់សំរាមដែលប្រសើរជាងមុន
- ពិភាក្សាអំពីលទ្ធផលដែលទទួលបាន (ពីសេចក្តីព្រាងដីកា)
- កំណត់ជំហានបន្ទាប់ ដើម្បីអោយការងារប្រព្រឹត្តទៅបានរលូន រហូតដល់បញ្ចប់ការធ្វើសេចក្តីព្រាងដីកានៅចុងខែមីនា ឆ្នាំ២០១៧

### ៣. ការពិនិត្យឡើងវិញ និងសម្រេចបញ្ចប់ការតាក់តែងសេចក្តីព្រាងដីកា

បន្ទាប់ពីពិភាក្សាលើសំណួរបើកចំហ លក្ខខណ្ឌច្បាប់ និងបណ្តុំគំនិតបន្ថែម នៅក្នុងសិក្ខាសាលាពាក់កណ្តាលការងារនេះរួចមក អនុក្រុមការងារបច្ចេកទេស១ បានបន្តធ្វើការងាររបស់ខ្លួន។ ចំណុចផ្តោតសំខាន់គឺការពិនិត្យឡើងវិញ ការកែតម្រូវ និងការសរសេរបញ្ចប់នូវខ្លឹមសាររបស់ដីកា ដើម្បីដាក់ដីកាក្នុងដំណើរការអនុម័ត។

ក្រុមប្រឹក្សាភិបាលនៃអភិបាលក្រុងដែលមានបុគ្គលិកសំខាន់ៗ នៅតាមនាយកដ្ឋានក្រុង និងការិយាល័យគ្រប់គ្រងសំរាម និងសោភ័ណ្ឌភាពទីក្រុងបានចូលរួមយ៉ាងជិតស្និទ្ធក្នុងដំណើរការនេះ។

### ៤. លទ្ធផលសំខាន់ៗនៃដីកាកម្រិតស្ថាប័ន - ទំនួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង

លទ្ធផលដែលសំខាន់មួយនៃដីកា គឺជាការបង្កើតក្រុមការងារបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹង ដែលមានទំនួលខុសត្រូវចម្បង ក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង ជាបន្តបន្ទាប់សម្រាប់ទីក្រុងបាត់ដំបងក្នុងទសវត្សន៍ក្រោយៗទៀត៖

- កំណត់ប្រព័ន្ធបែងចែកសំរាមនៅក្នុងយុទ្ធសាស្រ្តសេដ្ឋកិច្ច និងសង្គម ជាពិសេសសំរាមសរីរាង្គ និងសំរាមប្លាស្ទិក។
- ជូនដំណឹងទៅដល់ប្រជាជនដែលរស់នៅក្នុងតំបន់គោលដៅអំពីសារៈសំខាន់នៃការបែងចែកសំរាម
- លើកកម្ពស់អត្ថប្រយោជន៍នៃការបែងចែកសំរាមទៅដល់ប្រជាជន ដើម្បីលើកទឹកចិត្តឱ្យពួកគាត់ចូលរួមដោយមានទំនួលខុសត្រូវខ្ពស់
- សម្របសម្រួល និងបង្រៀនប្រជាជនអំពីរបៀបបែងចែកសំរាមដល់ពួកគាត់
- ជូនដំណឹងដល់អ្នកប្រមូលសំរាម និងអ្នកដែលរស់នៅក្បែរទីលានចាក់សំរាម អំពីផលប៉ះពាល់នៃការដុតសំរាមនៅទីលានចាក់សំរាម
- បង្កើតគម្រោងសាកល្បងមួយ និងកំណត់ដំណោះស្រាយសមស្របសម្រាប់ពន្លត់អគ្គីភ័យនៅទីលានចាក់សំរាម និងដើម្បីកែលម្អទីលានចាក់សំរាម
- លើកកម្ពស់អត្ថប្រយោជន៍នៃការបញ្ចេញ ការថែរក្សា ការបែងចែក ការប្រមូល និងការរក្សាសំរាមទៅឱ្យប្រជាជននៅតំបន់បេតិកភណ្ឌដើម្បីលើកទឹកចិត្តឱ្យពួកគេចូលរួម និងមានទំនួលខុសត្រូវខ្ពស់
- អនុវត្តសកម្មភាពបែងចែកសំរាមនៅតាមតំបន់បេតិកភណ្ឌ។

- សម្របសម្រួល និងបង្រៀនពីបច្ចេកទេសស្តីពីយុទ្ធសាស្ត្រពង្រឹងច្បាប់ក្នុងការគ្រប់គ្រងសំរាម ជូនដល់ប្រជាពលរដ្ឋនៅតំបន់បេតិកភណ្ឌ
- ប្រមូល និងកត់ត្រាទិន្នន័យអំពីសំរាមដែលត្រូវបានបង្កើតឡើងនៅទីក្រុងបាត់ដំបងសម្រាប់ត្រួតពិនិត្យ និងរាយការណ៍ទៅលើការកាត់បន្ថយការបំពុលអាកាសធាតុរយៈពេលខ្លី។
- ធ្វើគណនេយ្យកម្មទៅលើការបំពុលអាកាសធាតុរយៈពេលខ្លី តាមបរិមាណនៃសំរាមដែលត្រូវបានកត់ត្រា
- វិភាគ និងវាយតម្លៃទៅលើការកាត់បន្ថយការបំពុលអាកាសធាតុរយៈពេលខ្លី
- រក្សាទុកទិន្នន័យ ដែលបានគណនាដើម្បីប្រៀបធៀបមុន និងក្រោយគម្រោង
- រាយការណ៍លទ្ធផលពីដំណាក់កាលនីមួយៗ

## ២.៣ ដំណើរការដាក់ស្នើដីកាសម្រាប់ពិនិត្យឡើងវិញ និងពិគ្រោះយោបល់

ដើម្បីអោយច្បាប់មានប្រសិទ្ធភាពនៅទីក្រុងបាត់ដំបង ដីកានេះត្រូវដាក់ស្នើដល់ស្ថាប័ននៅថ្នាក់ក្រុង និងថ្នាក់ខេត្ត។ ដំណើរការនៃការដាក់ស្នើការពិនិត្យមើលឡើងវិញ ពិគ្រោះយោបល់ និងអនុម័តចុងក្រោយត្រូវបានបញ្ជាក់នៅក្នុងច្បាប់ជាតិនៃប្រទេសកម្ពុជា។ សូមមើលអនុក្រឹត្យលេខ ២៨៦ សម្រាប់ព័ត៌មានលំអិតបន្ថែម។

នៅទីក្រុងបាត់ដំបង ដំណើរការនៃការដាក់ស្នើ ពិនិត្យមើលឡើងវិញ ពិគ្រោះយោបល់ និងការអនុម័តចុងក្រោយត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

បន្ទាប់ពីពិនិត្យឡើងវិញ និងកែសម្រួលដីការួចមក ក្រុមការងារបច្ចេកទេសគ្រប់គ្រងកាកសំណល់រឹងបានដាក់សេចក្តីព្រាងដីកានេះ ទៅកាន់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការកិច្ចការស្ត្រី និងកុមារដើម្បីធ្វើការពិគ្រោះយោបល់ទៅលើខ្លឹមសារដីកា។ ជំហាននេះ គឺតម្រូវអោយធ្វើមុននឹងដាក់ស្នើចេញទៅកាន់ក្រុមប្រឹក្សាក្រុងពិភាក្សា។

បន្ទាប់មក ក្រុមប្រឹក្សាក្រុងរៀបចំកិច្ចប្រជុំបន្ទាប់ដើម្បីត្រួតពិនិត្យ និងពិគ្រោះយោបល់ លើសេចក្តីព្រាងដីកានេះ។ ក្រុមការងារក៏បានកែសម្រួលសេចក្តីព្រាងដីកា ទៅតាមសេចក្តីណែនាំរបស់ក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការទាំងពីរ មុននឹងដាក់សេចក្តីព្រាងដីកានេះ បន្តទៅកាន់ក្រុមប្រឹក្សាក្រុងដើម្បីត្រួតពិនិត្យ និងអនុម័ត។

បន្ទាប់ពីទទួលបានដីកា អភិបាលនៃគណៈអភិបាលក្រុងបាត់ដំបង រៀបចំកិច្ចប្រជុំចុងក្រោយ ដើម្បីធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងដីកា ដែលជាជំហានចុងក្រោយមុនពេលក្រុមប្រឹក្សាក្រុងមានការអនុម័តដើម្បីចាប់ផ្តើមជំហានបន្តនៅតាមថ្នាក់ខេត្ត។ ក្នុងករណីនេះ ដីកាដែលបានកែសម្រួល និងអនុម័តត្រូវបានដាក់ស្នើទៅរដ្ឋបាលខេត្តដើម្បីសុំយោបល់ និងពិនិត្យអំពីនីតិភាពរបស់ដីកា។

បន្ទាប់ពីទទួលបានមតិកែលម្អពីរដ្ឋបាលថ្នាក់ខេត្ត ក្រុមប្រឹក្សាក្រុងបាត់ដំបង ចាំបាច់ត្រូវតែធ្វើការកែសម្រួលសេចក្តីព្រាងដីកាដែលបានអនុម័តដំបូង បន្ទាប់មកបញ្ជូនទៅក្រុមប្រឹក្សាក្រុងជាថ្មីម្តងទៀត សម្រាប់ជំហានអនុម័តចុងក្រោយ មុនពេលដីកាអាចក្លាយទៅជាច្បាប់ប្រកបដោយប្រសិទ្ធភាពនៅក្នុងទីក្រុងបាត់ដំបង។




*បច្ចុប្បន្ន (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧) សេចក្តីព្រាងដីកានេះ កំពុងតែរង់ចាំការអនុម័តចុងក្រោយពីរដ្ឋបាល ក្រុមប្រឹក្សាខេត្ត។*

គន្លឹះ៖ គម្រោងនីមួយៗ មានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នា ហើយត្រូវតែមានភាពសមស្របនឹងបរិយាកាសជាក់ស្តែងនៃគម្រោងនោះ។ យើងសូមផ្តល់អនុសាសន៍ ទុកជាការពិចារណា និងឆ្លុះបញ្ចាំងពីសេណារីយ៉ូផ្សេងៗគ្នាក្នុងការបង្កើតក្រុមជំនាញ ក្រុមការងារ ពិភាក្សាដោយមានការចូលរួមពីភាគីសំខាន់ៗ អំពីដំណាក់កាលនីមួយៗនៃគម្រោង ដែលអាចធ្វើទៅបាន។ ជំហាននីមួយៗមានបញ្ហាប្រឈម ហានីភ័យ អ្នកពាក់ព័ន្ធ និងគោលបំណងផ្សេងៗគ្នា។ កាលណាអ្នករៀបចំជំហាននីមួយៗកាន់តែល្អ នោះវាក៏កាន់តែងាយស្រួលផងដែរ ក្នុងការអនុវត្តគម្រោងប្រកបដោយជោគជ័យ។ និយាយអោយខ្លីទៅ ភាពជោគជ័យត្រូវការរៀបចំដែលល្អ។




*រូបភាពនេះ បង្ហាញពីសិក្ខាកាមនៅក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអភិវឌ្ឍដីកា (ថ្ងៃទី៣០ ខែមិថុនាឆ្នាំ ២០១៧) សិក្ខាសាលាផ្សព្វផ្សាយនេះ ផ្តោតលើការអភិវឌ្ឍដីកាសម្រាប់ការគ្រប់គ្រងសំរាមរឹងនៅថ្នាក់ឃុំ និងដើរតួជាវេទិកាមួយ ដើម្បីផ្តល់ព័ត៌មានអំពីដំណើរការធ្វើសេចក្តីព្រាងនៅក្នុងទីក្រុងបាត់ដំបង និងដើម្បីចែករំលែកបទពិសោធន៍ នៅតាមឃុំ ភូមិនិងសង្កាត់ផ្សេងៗផងដែរ។*

# ៣ ចក្ខុវិស័យ - ជំហានបន្ទាប់

យោងតាមអនុក្រឹត្យលេខ១១៣ សាលារាជធានីភ្នំពេញតាមច្បាប់ គឺមានទំនួលខុសត្រូវចំពោះការគ្រប់គ្រងកាកសំណល់រឹង។ ការទទួលខុសត្រូវនេះ គឺសំខាន់បំផុតក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងក្រៅពីតម្រូវការនៃការអនុវត្ត និងការកសាងសមត្ថភាព។

> សាលាក្រុងមានសិទ្ធិរៀបចំការគ្រប់គ្រងកាកសំណល់រឹង
>
> ក. ដោយខ្លួនឯង ឬ
>
> ខ. ជាដៃគូជាមួយវិស័យឯកជន - ជាដៃគូជាមួយឯកជនសាធារណៈ ឬ
>
> គ. ចុះកិច្ចសន្យាជាមួយវិស័យឯកជនរួមក្នុងការគ្រប់គ្រងកាកសំណល់រឹងទាំងការដេញថ្លៃជាអន្តរជាតិ។ លទ្ធភាពទាំងអស់គួរតែត្រូវយកមកវាយតម្លៃ។

ជំហានខាងក្រោម គឺជាអនុសាសន៍សម្រាប់បង្កើតចងក្រងប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនៅក្រុងបាត់ដំបងនាពេលអនាគត។ អនុសាសន៍ទាំងនេះសុទ្ធតែស្រង់មកពីដីកា។ មានន័យថា អនុសាសន៍ទាំងនេះអាចអនុវត្តទៅបានដោយគ្មានបញ្ហាផ្លូវច្បាប់ ព្រោះថារាល់ខ្លឹមសារនានា សុទ្ធតែត្រូវបានអនុម័ត និងគាំទ្រដោយភាគីពាក់ព័ន្ធទាំងឡាយក្នុងការបង្កើតដីកា។

ជំហានទាំងនេះ គឺអាចអនុវត្តទៅបានចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០៣០ អាស្រ័យទៅលើធនធានដែលមាន (បុគ្គលិក និងថវិកា) សមត្ថភាពរបស់ស្ថាប័នរដ្ឋបាល។

| ការត្រួតពិនិត្យទៅលើការគ្រប់គ្រងកាកសំណល់រឹង | ការអនុវត្តដោយម៉ឺងម៉ាត់ | ការលើកកំពស់ការយល់ដឹង និងការគ្រប់គ្រងជាសាធារណៈ |
|---|---|---|
| ▪ ការប្រមូលកម្រៃដោយសាលាក្រុង<br>▪ ការបង្កើតថវិកាផ្ទាល់ខ្លួន<br>▪ ការពង្រឹងនូវសមត្ថភាពរបស់សាលាក្រុង<br>▪ កិច្ចសន្យារយៈពេលខ្លីជាមួយអ្នកផ្តល់សេវាកម្ម ឬការដេញថ្លៃជាលក្ខណៈអន្តរជាតិ<br>▪ ការត្រួតពិនិត្យ<br>▪ ការប្រមូល និងវិភាគទិន្នន័យ | ▪ វិធានការត្រជាក់៖ ការបង្កើនការយល់ដឹង និងការអប់រំ<br>▪ វិធានការត្រជាក់៖ ការលើកទឹកចិត្ត សម្រាប់ការអនុវត្តបានល្អ<br>▪ វិធានការក្តៅ៖ ការអនុវត្តច្បាប់<br>▪ វិធានការក្តៅ៖ ការផ្តន្ទាទោសចំពោះការរំលោភបំពានលើដីកា | ▪ យុទ្ធសាស្រ្តទំនាក់ទំនង<br>▪ AIDA និង KISS<br>▪ ឯកអគ្គរដ្ឋទូតទីក្រុងបៃតង<br>▪ វិស័យសាធារណៈគ្មានការប្រើប្រាស់ប្លាស្ទិក<br>▪ រង្វាន់វិស័យសាធារណៈគ្មានការប្រើប្រាស់ប្លាស្ទិក<br>▪ ទីក្រុងស្អាត<br>▪ កិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល<br>▪ គេហទំព័រការសំអាត អនាម័យនៅកម្ពុជា (អាចរកបាននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧) |

## ៣.១ ការគ្រប់គ្រងកាកសំណល់រឹងក្នុងក្រុងបាត់ដំបង

ដើម្បីធ្វើការកែលម្អ ការគ្រប់គ្រងកាកសំណល់រឹងឲ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវតែបង្កើន និងបង្កើតឡើងវិញនូវការគ្រប់គ្រង ត្រួតពិនិត្យអោយបានពេញលេញ ទៅលើការគ្រប់គ្រងកាកសំណល់រឹង។

មានន័យថា សាលាក្រុងបាត់ដំបងត្រូវការ៖

- *ទិន្នន័យច្បាស់លាស់*
- *យន្តការក្នុងការគ្រប់គ្រងអ្នកផ្តល់សេវា*
- *យុទ្ធសាស្ត្រជំហានបន្ទាប់*
- *មធ្យោបាយប្រាស្រ័យទាក់ទងដែលអាចទុកចិត្តបាន*
- *ការបែងចែកតួនាទីច្បាស់លាស់។*

និយាយម្យ៉ាងទៀត សាលាក្រុងបាត់ដំបងគួរតែប្រើប្រាស់គ្រប់មធ្យោបាយដែលមាន និងលទ្ធភាពស្របច្បាប់ទាំងអស់ដើម្បីអនុវត្តដីកា មួយជំហានៗ បើទោះជាភាគច្រើននៃបទបញ្ញត្តិទាំងនេះ តម្រូវឲ្យមាននីតិវិធីរដ្ឋបាលថ្មី និងការកំណត់តួនាទីថ្មីច្បាស់លាស់ក៏ដោយ។

វិធីសាស្ត្រនេះ ក៏អាចយកទៅអនុវត្តចំពោះការប្រមូលថ្លៃសេវាផងដែរ។ លុះត្រាណាតែសាលាក្រុងបាត់ដំបងត្រួតពិនិត្យប្រាក់ចំណូល នោះទើបសាលាក្រុងអាចគ្រប់គ្រង ចែកចាយ និងផាកពិន័យតាមជំហានដែលបានចែងនៅក្នុងអនុក្រឹត្យលេខ១១៣ និងដីកា។

## អនុសាសន៍

### ១. ការប្រមូលថ្លៃសេវាតាមរយៈសាលាក្រុង និងការបង្កើតថវិកាសាលាក្រុង

ការប្រមូលថ្លៃសេវាដែលមានតម្លាភាព គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះការគ្រប់គ្រងកាកសំណល់រឹង។ កញ្ចប់ថវិកាដ៏រឹងមាំមួយ គឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីផ្លែ និងបង្កើតឡើងនូវប្រព័ន្ធមួយដែលមានប្រសិទ្ធភាព។

បច្ចុប្បន្ន ថ្លៃសេវាត្រូវបានប្រមូលដោយក្រុមហ៊ុនស៊ិនទ្រី (CINTRI) ហើយគ្មាននរណាដឹងទេថាតើមានថវិកាប៉ុន្មាននៅសល់ សម្រាប់ការកែលម្អប្រព័ន្ធគ្រប់គ្រងសំរាម។ ព័ត៌មានលំអិតអំពីរបៀបដែលក្រុមហ៊ុនស៊ីនទ្រីប្រើប្រាស់ថវិកាសម្រាប់ការផ្លែប្រខិត ការវិនិយោគ ឬការកែលម្អប្រព័ន្ធគ្រប់គ្រងសំរាមក៏ពុំមានដែរ។

ប្រសិនបើសាលាក្រុងបាត់ដំបងចង់បង្កើតនូវប្រព័ន្ធគ្រប់គ្រងសំរាម ដែលមានលក្ខណៈសមរម្យមួយ នោះការប្រមូលថ្លៃសេវា ត្រូវតែស្ថិតនៅក្នុងកណ្តាប់ដៃរបស់សាលាក្រុង។ ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនាពេលអនាគត អាចអនុវត្តទៅបានលុះត្រាណាតែមានទិន្នន័យហិរញ្ញវត្ថុច្បាស់លាស់។

នេះតម្រូវឲ្យមានការប្រមូល និងការវិភាគទិន្នន័យយ៉ាងទូលំទូលាយក្នុងក្រុងបាត់ដំបង។ បន្ទាប់ពីមានការវិភាគទិន្នន័យហិរញ្ញវត្ថុ និងការចំណាយជាក់ស្តែងលើប្រព័ន្ធបច្ចុប្បន្ន ឧទាហរណ៍ដូចជាកិច្ចចរចាជាមួយអ្នកផ្គត់ផ្គង់អគ្គីសនី ទឹក និងអ្នកផ្គត់ផ្គង់សេវាផ្សេងៗទៀត ត្រូវតែធ្វើឡើងដើម្បីពិភាក្សាអំពីលទ្ធភាពដែលអាចធ្វើ

ទៅបាន។

**រាល់ការចំណាយ**លើការប្រមូល និងការចោលសំរាមចាំបាច់ត្រូវតែវិភាគ។ របាយការណ៍ហិរញ្ញវត្ថុរបស់អ្នកផ្តល់សេវាដែលមានលក្ខណៈពេញលេញ និងលម្អិតគឺចាំបាច់ត្រូវតែមាន។

**គំនិតសម្រាប់ការអនុវត្តជាក់ស្តែងនាពេលអនាគត៖**

ការបង្កើតកម្មវិធីតាមស្មាតហ្វូនសម្រាប់ការប្រមូលប្រាក់។ កម្មវិធីនេះគួរតែមានលក្ខណៈសមស្រប សម្រាប់ទំរង់នៃការប្រមូលប្រាក់ផ្សេងៗគ្នា ដូចជា ពីគ្រួសារមួយទៅគ្រួសារមួយ ការបង់ប្រាក់តាមអ៊ីនធឺណេត ការផ្ទេរប្រាក់ ។ល។ ដើម្បីបំពេញទៅតាមលក្ខខណ្ឌផ្សេងៗគ្នានៃប្រជាជន។

កម្មវិធីនេះអាចប្រើបានដើម្បីត្រួតពិនិត្យការប្រមូលប្រាក់។ វាអាចតភ្ជាប់ទៅពេលវេលាពិតរបស់ទិន្នន័យក្នុងធនាគារនៃប្រព័ន្ធការគ្រប់គ្រងកាកសំណល់រឹង។ ឧទាហរណ៍៖ អាចបង្ហាញឲ្យឃើញអ្នកប្រើទាំងអស់នៅលើផែនទី ព្រមទាំងស្ថានភាពនៃការបង់ប្រាក់របស់ពួកគេ។

ពាក្យបណ្តឹង ការរំលោភបំពាន ការពិន័យ និងប្រធានបទផ្សេងៗទៀតជាច្រើនអាចគ្រប់គ្រងបានដោយកម្មវិធីនេះ។

ការបង្ហាញពីពេលវេលាពិតនៅលើផែនទីអាចអនុញ្ញាតឱ្យសាធារណជនចូលមើលទិន្នន័យសំខាន់ៗ ដែលបង្ហាញពីតម្លាភាព។

**អនុសាសន៍៖**

មូលដ្ឋានទិន្នន័យសម្រាប់កម្មវិធីបែបនេះ ត្រូវតែមានភាពទូលំទូលាយ និងរឹងមាំ។ ការបង្កើតកម្មវិធីបែបនេះ និងទិន្នន័យរបស់ធនាគារត្រូវផ្អែកលើមូលដ្ឋាននៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រទំនើប។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រទំនើប គឺជាឧបករណ៍ដ៏មានឥទ្ធិពល សម្រាប់គ្រប់គ្រងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដែលអាចធ្វើអោយរដ្ឋបាលមូលដ្ឋានមានភាពប្រសើរឡើង។

## ២. កិច្ចសន្យាថ្មី រយៈពេលខ្លីជាមួយអ្នកផ្តល់សេវាសាធារណៈ - ការដេញថ្លៃអន្តរជាតិ - ដៃគូឯកជនសាធារណៈ

យោងតាមអនុក្រឹត្យលេខ១១៣ កិច្ចសន្យាជាមួយអ្នកផ្តល់សេវាសាធារណៈទាំងអស់ ត្រូវតែធ្វើការចរចាឡើងវិញ។ មានតែកិច្ចសន្យាអន្តរកាល (transitional contracts) ប៉ុណ្ណោះ ទើបអាចអនុញ្ញាតឲ្យមានសុពលភាពអតិបរមា ៣ឆ្នាំ។ ថ្លៃសេវា ត្រូវតែផ្អែកលើការគណនាជាក់ស្តែង។

ដើម្បីធ្វើការគណនានេះបាន គេត្រូវតែប្រមូល ហើយវិភាគទិន្នន័យក្នុងកំឡុងពេល១ឆ្នាំ។ ទន្ទឹមនឹងនេះ ប្រព័ន្ធតម្លៃចាស់ ត្រូវតែយកមកអនុវត្ត និងកែលម្អរហូតដល់ការកំណត់តម្លៃថ្មីត្រូវបានបង្កើតឡើងដោយផ្អែកលើតម្លៃជាក់ស្តែង។

ទិន្នន័យត្រូវតែរួមបញ្ចូល៖

- ការប្រមូល និងការវិភាគទិន្នន័យប្រជាសាស្ត្រ ដូចជាការអភិវឌ្ឍចំនួនប្រជាជន ដង់ស៊ីតេប្រជាជន អាយុនិងភេទ ស្ថានការណ៍សេដ្ឋកិច្ច អត្រាការងារ ។ល។
- ការប្រមូល និងការវិភាគទិន្នន័យបច្ចេកទេស ដូចជាអត្រាគ្របដណ្តប់ (ផ្ទៃ) អត្រាការប្រមូល និងប្រេកង់ប្រមូល ចំណុចប្រមូល អត្រាសេវាកម្មជាក់ស្តែង អត្រាប្រមូលថ្លៃ
- ការប្រមូល និងការវិភាគឧបករណ៍បច្ចេកទេស (ចំនួនឡានដឹកទំនិញ សិក្ខាសាលា អគារ សម្ភារ ធុងសំរាម ចំណុចប្រមូល ឧបករណ៍ ។ល។ ដែលរួមមានតម្រូវការសម្ភារ ប្រេងសាំង និងទំនិញប្រើប្រាស់ផ្សេងៗទៀត
- ការប្រមូល និងការវិភាគទិន្នន័យអំពីបុគ្គលិកដែលមាន (អ្នកបើកបរ កម្មករជំនាញនិងមិនជំនាញ អ្នកបច្ចេកទេស រដ្ឋបាល អ្នកគ្រប់គ្រង)
- ការប្រមូល និងការវិភាគទិន្នន័យហិរញ្ញវត្ថុរួមទាំងប្រាក់ចំណូលទាំងអស់ (ថ្លៃឈ្នួល ការពិន័យ ជំនួយ និងប្រាក់កម្ចី) និងការចំណាយទាំងអស់ (ប្រាក់ខែ ថ្លៃរត់ ថ្លៃដើម ដូចជាដើមទុននិងការប្រាក់ជាដើម)

បន្ទាប់ពីប្រមូលទិន្នន័យ និងវិភាគភាពប្រែប្រួល និងភាពខុសគ្នានៃប្រព័ន្ធនេះ យើងអាចពិនិត្យ និងគណនាការចំណាយទៅលើការអភិវឌ្ឍប្រព័ន្ធនៃការគ្រប់គ្រងកាកសំណល់រឹង នាពេលអនាគត។ ការវិភាគបែបនេះមានលក្ខណៈទូលំទូលាយហើយទាមទារអោយមានបុគ្គលិកដែលមានសមត្ថភាព និងការគាំទ្រពីអ្នកជំនាញការដែលមានបទពិសោធន៍។ សូមយោងទៅលើឧទាហរណ៍ដែលបានផ្តល់ក្នុងរូបថតខាងក្រោម។

**ប៉ារ៉ាម៉ែត្របម្រែបម្រួលនៃការគ្រប់គ្រងកាកសំណល់រឹង - ការប្រមូល និងការដឹងជញ្ជូន**

| រយៈពេលនៃការប្រើប្រាស់ | ចំនួនឆ្នាំ |
|---|---|
| ត្រាក់ទ័រ | 8 |
| រម៉ក់សណ្តោងសម្រាប់ ត្រាក់ទ័រ | 10 |
| រថយន្តដឹកជញ្ជូន (មួយទឹក) | 5 |
| រថយន្តដឹកជញ្ជូន (ថ្មី) | 10 |
| រថយន្តបង្រួមសំណល់ | 12 |
| រថយន្តប្រមូលសំណល់កែច្នៃ | 12 |
| ធុងសំរាមសាធារណៈ | 5 |
| ធុងសំរាម | 8 |

| ការផ្លាស់ប្តូរចំណាយវិនិយោគប្រចាំឆ្នាំ | +%/-% |
|---|---|
| រថយន្តប្រមូល និងដឹកជញ្ជូន | 0,00% |
| ឧបករណ៍បច្ចេកទេស | 0,00% |

| ការផ្លាស់ប្តូរចំណាយលើការដំណើរការប្រចាំឆ្នាំ | +%/-% |
|---|---|
| ចំណាយលើការដំណើរការ | 0,00% |

**ការប្រាក់** *(p.a.៖ ក្នុងមួយឆ្នាំ)*

| | | |
|---|---|---|
| អត្រាការប្រាក់ពិត i | 3,00% | p.a. |
| អត្រាកើនឡើង r | | |
| ចំណាយលើការវិនិយោគឡើងវិញ rIC | 0,00% | p.a. |
| ចំណាយលើការវិនិយោគឡើងវិញ rIC | | |
| បៀវត្សរ៍ | 0,00% | p.a. |
| ចំណាយលើការថែទាំ | 0,00% | p.a. |
| រថយន្តដឹកជញ្ជូន | | |
| ចំណាយលើការរថយន្តដឹងជញ្ជូន | 0,00% | p.a. |
| ឥន្ទនៈ | | |
| ប្រេង | | |
| ចំណាយដំណើរការលើរថយន្តដឹកជញ្ជូន | 0,00% | p.a. |
| ចំណាយរដ្ឋបាល | 0,00% | p.a. |

| សេវាកម្ម | លេខ |
|---|---|
| ប្រជាជន | 6000 |
| អចលនវត្ថុ | 1000 |
| ធុងសំរាម | 1000 |

*ឧទាហរណ៍១៖ ការវិភាគចំណាយលើអាយុកាលនៃប្រព័ន្ធ បញ្ចូលប៉ារ៉ាម៉ែត្រសម្រាប់ការប្រមូល និងដឹកជញ្ជូនតែប៉ុណ្ណោះ ដើម្បីការវិភាគមានភាពទូលំទូលាយ*

*ឧទាហរណ៍២៖ រូបថតនៃសៀវភៅបញ្ជីសម្រាប់ការវិភាគហិរញ្ញវត្ថុនៃប្រព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹង (ការប្រៀបធៀបតម្លៃថាមវន្ត) នៃបម្រែបម្រួលដែលអាចកើតមានឡើង៖ "ការប្រមូលសំរាមតាមដងផ្លូវដោយរថយន្តតូច និងដឹកជញ្ជូនទៅទីលានចាក់សំរាម"*

| កូដ | ទីតាំង | សម្គាល់ | តម្លៃឯកតា | ចំនួន | ការវិនិយោគ | ចំណាយដំណើរការ | រយៈពេលវាយតម្លៃ | ៤០ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| | | | | | | | ចំណាយវិនិយោគ-រ | ND |
| 100 | ផែនការ និងការអប់រំ | | | | | | | |
| 101 | ផែនការ ការវាយតម្លៃ ការសិក្សា ។ល។ | ១០% នៃចំណាយវិនិយោគ | | | | | | |
| 102 | ការអភិវឌ្ឍសមត្ថភាពចំណាយ | សម្រាប់អ្នកប្រើប្រាស់ | | | | | | |
| 200 | ធុងសំរាមឯកជន | | | | | | | |
| 201 | ធុងសំរាម - ការរៀបចំតំបន់សាធារណៈ | | | | | | | |
| 202 | គ្រឹះ (ប្រសិនបើអាចអនុវត្តបាន) | | | | | | | |
| 203 | ចំណាយក្នុងការថែទាំ | ១០% នៃចំណាយវិនិយោគ កូដ 201 | | | | | | |
| 300 | ចំណុចប្រមូល | | | | | | | |
| 301 | ធុង (លាយគ្នា) | ១០០ លីត្រ | | | | | | |
| 302 | ធុង (ប្រភេទសំណល់ផ្សេងគ្នា) | ៦០ លីត្រ | | | | | | |
| 303 | ធុង (បំរុង) | ១០០ លីត្រ ១៥%នៃចំនួនសរុប | | | | | | |
| 400 | ការប្រមូល និងការដឹកជញ្ជូន | | | | | | | |
| 410 | ចំណាយលើរថយន្តដឹងជញ្ជូន | | | | | | | |
| 411 | KIA - រថយន្តតូច (មួយទឹក) | | | | | | | |
| 412 | ពន្ធប្រចាំឆ្នាំ | កូដ 411 | | | | | | |
| 413 | រថយន្តបង្រួម ៣០ម³ (ថ្មី) | រួមបញ្ចូលទាំងថ្លៃដឹកជញ្ជូន | | | | | | |
| 414 | អាករបន្ថែម (១០%) + ពន្ធនាំចូល (៥%) | ១៥% នៃចំណាយវិនិយោគ កូដ 313 | | | | | | |
| 415 | ពន្ធលើការប្រើប្រាស់ (ប្រសិនបើអាចអនុវត្តបាន) | ក្រោម ១៥០០ សម³ | | | | | | |
| 416 | ពន្ធផ្សេងៗ (ប្រសិនបើអាចអនុវត្តបាន) | កូដ 413 | | | | | | |
| 420 | ចំណាយថែទាំ | | | | | | | |
| 421 | ចំណាយថែទាំរថយន្តប្រចាំឆ្នាំ (ថ្មី) | ១០% នៃចំណាយវិនិយោគ កូដ 413 | | | | | | |
| 422 | ចំណាយថែទាំរថយន្តប្រចាំឆ្នាំ (មួយទឹក) | ១៥% នៃចំណាយវិនិយោគ កូដ 411 | | | | | | |
| 430 | ចំណាយលើបុគ្គលិកដឹកជញ្ជូន | | | | | | | |
| 431 | ប្រាក់បៀវត្សរ៍ប្រចាំឆ្នាំសម្រាប់អ្នកបើកបរ | | | | | | | |
| 432 | ប្រាក់បៀវត្សរ៍ប្រចាំឆ្នាំសម្រាប់កម្មករផ្តល់សេវា | រួមបញ្ចូលទាំងពលកម្មបន្ថែម (ដោយសារវិស្សមកាល ជំងឺ) | | | | | | |
| 433 | ចំណាយពលកម្មអ្នកបើកបរស្ម័គ្រចិត្ត | ប្រាក់បៀវត្សរ៍ ៤ខែ កូដ 431 | | | | | | |
| 434 | ចំណាយពលកម្មកម្មករផ្តល់សេវាស្ម័គ្រចិត្ត | ប្រាក់បៀវត្សរ៍ ៤ខែ កូដ 432 | | | | | | |
| 440 | ចំណាយដំណើរការសំរាប់រថយន្ត | | | | | | | |
| 441 | ឥន្ធនៈ (គិតជាលីត្រ) | តម្រូវការ ១៣លីត្រក្នុង ១០០គីឡូម៉ែត្រ | | | | | | |
| 442 | ប្រេងម៉ាស៊ីន (គិតជាលីត្រ) | ២លីត្រក្នុង ១០០០គីឡូម៉ែត្រ | | | | | | |
| 500 | ចំណាយរដ្ឋបាល | ២០% នៃការចំណាយលើរថយន្ត ចំណាយដំណើរការ និងបៀវត្សរ៍ | | | | | | |
| 600 | ចំណាយលើការអភិវឌ្ឍសមត្ថភាព | សម្រាប់អ្នកប្រើប្រាស់ ក្រុមហ៊ុនបម្រើសេវាកម្ម និងក្រុង | | | | | | |
| | សរុប | | | | | | | |
| | តម្លៃប្រចាំឆ្នាំ (តម្លៃបច្ចុប្បន្ន សន្និដ្ឋាន) សម្រាប់ការប្រមូល និងដឹកជញ្ជូន | | | | | | | |

***ចំណាំ៖***

ដើម្បីធ្វើការសម្រេចចិត្តទៅលើការអភិវឌ្ឍប្រព័ន្ធ ការគ្រប់គ្រងកាកសំណល់រឹងបន្ថែមទៀត ការវិភាគបែបនេះគឺត្រូវតែចាំបាច់។ ការសម្រេចចិត្តគួរតែត្រូវធ្វើឡើងដោយផ្អែកលើការវាយតម្លៃលើហិរញ្ញវត្ថុ បរិស្ថាន និងសេដ្ឋកិច្ចសង្គម។

ដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ដែលរដ្ឋបាលមូលដ្ឋានអាចធ្វើការវិភាគ ដើម្បីគ្រប់គ្រងដំណើរការវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអោយមាននិរន្តរភាព។ បើគ្មានសមត្ថភាពបែបនេះនៅក្នុងរដ្ឋបាល និងគ្មានការកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសាធារណៈនោះទេ ការអភិវឌ្ឍ និងការគ្រប់គ្រងសំរាមរឹងនៅកម្ពុជានាពេលបច្ចុប្បន្ននឹងមានភាពលំបាកយ៉ាងខ្លាំង។

ការវាយតម្លៃនេះ នឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃកិច្ចសន្យាចរចារវាងក្រុង និងអ្នកផ្តល់សេវាកម្ម ប៉ុន្តែការវាយតម្លៃនេះ នៅតែជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់ការសម្រេចចិត្តផ្នែកនយោបាយណាមួយ។

**កិច្ចសន្យាចរចាជាមួយអ្នកផ្តល់សេវាកម្ម**

អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំ គួរតែត្រូវបានជូនដំណឹងអំពីព័ត៌មានលម្អិតនៃកិច្ចសន្យា ខ្លឹមសារដីកា និងច្បាប់ដែលពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងព័ត៌មានលម្អិតពីស្ថានភាពកាកសំណល់បច្ចុប្បន្ន។

*បញ្ហាសំខាន់ៗទាក់ទងនឹងកិច្ចសន្យា៖*

- ក្នុងរយៈពេលអន្តរកាល ៣ឆ្នាំ (ក្នុងរយៈពេល ៣ឆ្នាំនេះ អ្នកផ្តល់សេវាត្រូវបង្ហាញឱ្យច្បាស់ថា គាត់មានសមត្ថភាពក្នុងការគ្រប់គ្រងប្រព័ន្ធទុកដាក់កាកសំណល់)
- អ្នកផ្តល់សេវាត្រូវតែផ្តល់ផែនការវិនិយោគសម្រាប់ពេលអនាគត និង***ចក្ខុវិស័យស្រមាប់ការច្នៃប្រឌិត!*** នេះរួមបញ្ចូលទាំង៖
    - ផែនការអាជីវកម្មលម្អិត
    - ផែនការហិរញ្ញវត្ថុលម្អិត រួមទាំងការវិនិយោគទាំងអស់ ការចំណាយដើមទុន ការធ្លាក់ចុះនៃតម្លៃ ការចំណាយមូលធនផ្សេងៗទៀត ដូចជាប្រាក់កម្ចី ប្រាក់ឧបត្ថម្ភ ការប្រាក់។ល។
    - សកម្មភាពដែលត្រូវការដើម្បីបំពេញនូវសេចក្តីត្រូវការរបស់សាលាក្រុងបាត់ដំបង
    - ផែនការស្តីពីដំណាក់កាលរៀបចំហិរញ្ញវត្ថុ និងបច្ចេកទេសរយៈពេលវែង

លុះត្រាណាតែ អ្នកផ្តល់សេវាកម្មមានលទ្ធភាពបំពេញនូវលក្ខណ្ឌដែលបានរៀបរាប់ខាងលើបាន នោះទើបសាលាក្រុងគួរពិចារណាអំពីការបន្តកិច្ចសន្យា!
បើមិនដូច្នេះទេ ការដេញថ្លៃអន្តរជាតិសម្រាប់ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងទីក្រុងបាត់ដំបងគួរតែត្រូវរៀបចំ។

### ៣. ការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំឲ្យបានសមរម្យ

ក្នុងអំឡុងពេលនៃគម្រោង ភាគីពាក់ព័ន្ធបានជួបគ្នាជាទៀងទាត់ ដើម្បីពិភាក្សាអំពីខ្លឹមសាររបស់ដីកា។ វាជាការសំខាន់ណាស់ក្នុងការរក្សាស្មារតីក្រុមឱ្យនៅរស់រវើក និងប្រើក្រុមការងារដែលមានស្រាប់ ដើម្បីធ្វើការអនុវត្តគម្រោង។ កិច្ចប្រជុំនីមួយៗ គួរតែធ្វើទៅតាមកាលវិភាគ មានរបៀបវារៈ និងការណែនាំច្បាស់លាស់។ សមាជិកម្នាក់ៗ ត្រូវតែយល់ដឹងពីតួនាទី និងសិទ្ធិរបស់ខ្លួន។ នៅក្នុងន័យនេះ តួនាទី ភារកិច្ច និងសិទ្ធិត្រូវតែកំណត់ឲ្យបានច្បាស់លាស់។

ទាំងនេះត្រូវបានរៀបរាប់នៅក្នុងជំពូក២ នៃដីកា។ សេចក្តីណែនាំនេះ គួរតែមានបង្ហាញពីយន្តការដើម្បីដោះស្រាយបញ្ហា និងបន្ទាត់គណនេយ្យភាព។

របៀបវារៈគួរតែត្រូវបានចែកចាយយ៉ាងហោចណាស់ពីរសប្តាហ៍មុនកិច្ចប្រជុំ៖

- តួនាទី និងភារកិច្ចត្រូវតែបានកំណត់ និងជូនដំណឹងយ៉ាងច្បាស់លាស់ (Organigram, Single Pager)
- រៀបចំសេចក្តីណែនាំ ពីទំនាក់ទំនងដែលស្របតាមគោលការណ៍សំខាន់ៗ ដូចជាការចូលរួម តម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធពល (សេចក្តីណែនាំ)
- កំណត់កិច្ចប្រជុំសម្រាប់ឆ្នាំទី១
- កំណត់ភាពញឹកញាប់នៃការចេញរបាយការណ៍សម្រាប់ឆ្នាំទី១

### ៤. ការបង្កើតយន្តការត្រួតពិនិត្យ

ការរំលោភលើដីកា ត្រូវតែបានធ្វើការកត់ត្រាជាឯកសារយ៉ាងត្រឹមត្រូវ និងមានតម្លាភាព។ ដើម្បីធ្វើដូច្នេះបាន វាចាំបាច់ក្នុងការបង្កើតគោលការណ៍ណែនាំ អំពីរបៀបកត់ត្រាឯកសារ។ បន្ថែមទៅលើធនាគារទិន្នន័យសម្រាប់ការកត់ត្រាការរំលោភលើដីកា និងបញ្ហាដែលទាក់ទងទៅនឹងការអនុវត្តរបស់វា គួរតែត្រូវបង្កើតឡើង។

កាតព្វកិច្ចក្នុងការរាយការណ៍ (ឧទាហរណ៍៖ ដោយអ្នកផ្តល់សេវាកម្ម ឬភាគីពាក់ព័ន្ធផ្សេងទៀត) គួរតែត្រូវបានអនុវត្តផងដែរ។ អ្នកពាក់ព័ន្ធនីមួយៗ ត្រូវតែមានកាតព្វកិច្ចក្នុងការរាយការណ៍ប្រាប់អ្នកពាក់ព័ន្ធដទៃទៀត អំពីសកម្មភាពបញ្ហាប្រឈម និងជំហានបន្ទាប់ ទាក់ទងនឹងការអនុវត្តរបស់ដីកា និងការកែលម្អប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនៅទីក្រុងបាត់ដំបង។

### ៥. ការប្រមូលទិន្នន័យអំពីការគ្រប់គ្រងកាកសំណល់រឹង

អ្នកផ្តល់សេវាកម្ម ត្រូវមានកាតព្វកិច្ចប្រគល់ទិន្នន័យដល់សាលាក្រុង និងក្រុមការងារបច្ចេកទេសអំពីបរិមាណកាកសំណល់ដែលប្រមូលប្រចាំថ្ងៃ សមាសភាពកាកសំណល់ ការគ្របដណ្តប់នៃតំបន់សេវា ផ្លូវនៃការប្រមូល និងចំនួនដងនៃការប្រមូល។

ទិន្នន័យនេះ គឺត្រូវការដើម្បីប្រើប្រាស់ប្រៀបធៀបតួលេខ និងបកប្រែពីនិន្នាការទាក់ទងទៅនឹងការអភិវឌ្ឍ និងដំណើរការនៃប្រព័ន្ធ។ សាកលវិទ្យាល័យ និងអ្នកជំនាញអាចចូលរួមក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ និងដំណើរការគ្រប់គ្រង។

## ៣.២ ការអនុវត្តដោយម៉ឺងម៉ាត់ វិធានការត្រជាក់ និងវិធានការក្តៅ (Sweet and Sour)

### *វិធានការត្រជាក់*

សូមចាប់ផ្តើមជាមួយនឹងការបង្កើតយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ អំពីអត្ថប្រយោជន៍នៃប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង (SWM) ដែលល្អ។ គោលបំណងក្នុងការបង្កើតដីកា ត្រូវតែបង្ហាញយ៉ាងច្បាស់ដល់ប្រជាពលរដ្ឋ ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀតផងដែរ។ ប្រសិនបើប្រជាជនគោរពតាមដីកា នោះផលប្រយោជន៍ដែលពួកគាត់នឹងទទួលបានមានច្រើន ដូចជា៖ ភាពប្រសើរឡើងនៃសុខភាពសាធារណៈ បរិយាកាសល្អ ស្អាត និងការលើកទឹកចិត្តខ្លួនឯង (ដូចដែលបានរៀបរាប់នៅក្នុងដីកា)។

ប្រើយុវទូតបៃតង (Green Ambassadors) យុវជនដែលមានសន្ទុះទឹកចិត្តផុសផុល និងការជួបប្រជុំដើម្បីផ្សព្វផ្សាយពីខ្លឹមសាររបស់ដីកា។ យុវទូតបៃតង អាចពន្យល់ពីអវិជ្ជមាននៃការចាក់សំរាម និងការដុតសំរាមដោយខុសច្បាប់ ដល់ប្រជាជន ក្រុមហ៊ុន អង្គការ។ ការប្រាស្រ័យទាក់ទងជាមួយនរណាម្នាក់ដែលមិនគោរពតាមដីកា គួរតែធ្វើឡើងតាំងពីដំបូង។

### *វិធានការក្តៅ*

អនុវត្តច្បាប់ដោយគ្មានការលើកលែង។ ប្រសិនបើពលរដ្ឋយល់ថា ដីកាមិនមែនត្រឹមតែជាក្រដាស ប៉ុន្តែជាញត្តិ ដែលនឹងត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ ហើយការអនុវត្តនេះនឹងធ្វើអោយមានការឈឺចាប់ (ការផាកពិន័យ។ ល។) នោះពួកគាត់នឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់។

**ឧទាហរណ៍៖**

- ប្រសិនបើផ្សារណា មិនធ្វើការបែងចែកកាកសំណល់តាមប្រភេទនោះទេ ផ្សារនោះនឹងត្រូវទទួលការពិន័យ (ម្តងហើយម្តងទៀតប្រសិនបើចាំបាច់)។
- ប្រសិនបើអ្នកប្រតិបត្តិទីលានចាក់សំរាមណា មិនបញ្ឈប់ការដុតសំរាមនោះទេ អ្នកប្រតិបត្តិទាំងនោះ នឹងត្រូវបានពិន័យ (ម្តងហើយម្តងទៀតប្រសិនបើចាំបាច់)។

## ៣.៣ យុទ្ធនាការលើកកម្ពស់ការយល់ដឹង

អជ្ញាធរមូលដ្ឋាន និងសមាជិកក្រុមបច្ចេកទេស ត្រូវមានតួនាទីក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ។ គោលបំណងគឺដើម្បីពន្យល់ប្រាប់ប្រជាពលរដ្ឋអំពីគោលការ R បី (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃ) និងការអនុវត្តដីកាថ្មី។

### អនុសាសន៍

បង្កើតផែនការទំនាក់ទំនងតាមគោលការណ៍ទីផ្សារ៖ AIDA (យកចិត្តទុកដាក់ > ចំណាប់អារម្មណ៍ > បំណង

ប្រាថ្នា > សកម្មភាព) និង KISS (រក្សាវាឱ្យខ្លី និងសាមញ្ញ)។

ជាដំបូង ការវិភាគស្ថានភាពជាក់ស្តែងនៅឃុំសង្កាត់ សាលារៀន ផ្សារ និងលំនៅដ្ឋាន គួរតែត្រូវបានធ្វើឡើង ដើម្បីស្វែងយល់ពីបញ្ហាបច្ចុប្បន្ន និងបញ្ហាដែលធ្លាប់កើតមាន។ អ្នកពាក់ព័ន្ធទាំងអស់គួរចូលរួមយ៉ាងសកម្ម។

**យុទ្ធសាស្ត្រមួយចំនួនដែលអាចធ្វើទៅបាន៖**

- ជ្រើសរើសយុវទូតទីក្រុងបៃតង (Green City Ambassadors ) ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងនៅតាមសាលារៀន សាកលវិទ្យាល័យ វត្តអារាម សង្កាត់ និងផ្សារជាដើម។ល។
  - ១ កំណត់ភារកិច្ចដូចជាការលើកកំពស់ការយល់ដឹង ការកត់ត្រាជាឯកសារ ការផ្តល់ជំនួយ ការផ្តល់សម្ភារ ការកំណត់កាលវិភាគ ការកំណត់ក្រុមគោលដៅ និងការបណ្តុះបណ្តាល
  - ២ បង្កើតយុទ្ធសាស្ត្រជ្រើសរើសសមាជិក
  - ៣ បង្កើតវគ្គបណ្តុះបណ្តាលសម្រាប់យុវទូតទីក្រុងបៃតង (សិក្ខាសាលាមួយថ្ងៃ)
- ផ្តល់រង្វាន់លើកទឹកចិត្តដល់ភោជនីយដ្ឋានណាដែលគ្មានថង់ប្លាស្ទិក ដើម្បីជំរុញការអនុវត្តល្អ (យុវទូតក្រុងបៃតងអាចធ្វើជាអ្នកជំរុញការខិតខំនេះ)
- ធ្វើឲ្យវិស័យសាធារណៈគ្មានថង់ប្លាស្ទិក (យុវទូតក្រុងបៃតងអាចធ្វើជាអ្នកជំរុញការខិតខំនេះ)
- ធ្វើឲ្យសាលារៀនគ្មានថង់ប្លាស្ទិក (យុវទូតក្រុងបៃតងអាចធ្វើជាអ្នកជំរុញការខិតខំនេះ) ឧទាហរណ៍៖ *ការប្រកួតប្រជែងការមិនបំភាយកាកសំណល់*
- រៀបចំការប្រកួតប្រជែងសណ្តាប់ធ្នាប់រវាងសង្កាត់ និងសង្កាត់៖ *ពានរង្វាន់ទីក្រុងស្អាត*
- រៀបចំធ្វើការចែករំលែកពីបទពិសោធន៍ល្អៗ
- បង្កើនចំនួនធុងសំរាមនៅទីសាធារណៈ ហើយអប់រំដល់ប្រជាពលរដ្ឋអំពីវិធីប្រើ (ប័ណ្ណប្រកាស)
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដូចជាអង្គការមិនប្រើប្រាស់ប្លាស្ទិកកម្ពុជា និងអង្គការដែលសកម្មដទៃទៀតក្នុងការគ្រប់គ្រងកាកសំណល់រឹង។

# ៨ សេចក្តីសន្និដ្ឋាន

ដីកាគឺជាជំហានដំបូង ឆ្ពោះទៅរកការធ្វើសេចក្តីព្រាងបទបញ្ញត្តិទូទៅនៅថ្នាក់ឃុំ ក៏ដូចជាជំហានដំបូងឆ្ពោះទៅរកវិធានការដើម្បីដោះស្រាយបញ្ហាកាកសំណល់រឹងផងដែរ។ ផ្អែកលើបទពិសោធន៍របស់គម្រោង គេអាចសន្និដ្ឋានបានថាមានការចាប់អារម្មណ៍ខ្ពស់ក្នុងចំណោមភាគីពាក់ព័ន្ធទាំងឡាយដែលបានចូលរួមយ៉ាងសកម្ម។

ដីកានេះគឺជាគោលការណ៍ណែនាំដ៏សំខាន់មួយសម្រាប់ទីក្រុងបាត់ដំបងហើយបានរួមបញ្ចូលនូវតម្រូវការនៃវិធានការរយៈពេលខ្លី និងផ្តល់គ្រឹះជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍវិស័យគ្រប់គ្រងកាកសំណល់រឹងនៅក្នុងទីក្រុងបាត់ដំបងទៅពេលខាងមុខ។

ដីកានេះពិពណ៌នា និងកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នាផងដែរ បានផ្តល់នូវក្របខ័ណ្ឌច្បាប់សម្រាប់ប្រជាពលរដ្ឋទាំងអស់ រួមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ។

ដើម្បីសម្រេចបានការអនុវត្តជាក់ស្តែងនៃដីកានេះ យន្តការទំនាក់ទំនងអចិន្ត្រៃយ៍ និងទៀងទាត់ ត្រូវតែបង្កើតឡើង ហើយកំណែទម្រង់រដ្ឋបាលត្រូវតែធ្វើឡើង។ ដីកាត្រូវបានតាក់តែងឡើងក្នុងមធ្យោបាយមួយ ដែលនឹងអនុញ្ញាតឱ្យទីក្រុងបាត់ដំបង ក្លាយទៅជាទីក្រុងដែលមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងតាមបែបទំនើបដោយសមត្ថភាពខ្លួនឯងមិនត្រូវការការគាំទ្រពីខាងក្រៅឡើយ។

ដូច្នេះ វាត្រូវបានផ្តល់អនុសាសន៍ អោយអនុវត្តជាជំហានៗ ដោយសន្សឹមៗ ជាជាងការអនុវត្តលឿនលោតផ្លោះដែលធ្វើអោយភាគីពាក់ព័ន្ធមិនអាចចាប់ដំណើរការបាន។ភាគីពាក់ព័ន្ធទាំងអស់សុទ្ធតែអាចធ្វើវិភាគទានមានតម្លៃ និងរួមចំណែកដល់ចក្ខុវិស័យរួម ប្រសិនបើពួកគេត្រូវបានបញ្ចូល ឲ្យដំណឹង និងដឹងឮព័ត៌មាននៃដំណើរការអនុវត្ត។

# ៥ ឯកសារយោង និងព័ត៌មានបន្ថែម

## ប្រភពនៃទិន្នន័យមូលដ្ឋានលើការគ្រប់គ្រងកាកសំណល់រឹង

មុនពេលនឹងដំណើរការតាក់តែងសេចក្ដីព្រាងដីកានេះ អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) បានធ្វើការវាយតម្លៃអំពីស្ថានភាពបច្ចុប្បន្ន នៃការគ្រប់គ្រងកាកសំណល់រឹងនៅខេត្តបាត់ដំបង តាងនាមឲ្យមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា។ អង្គការ COMPED មានបទពិសោធន៍ជាង១៥ឆ្នាំ មកហើយលើវិស័យគ្រប់គ្រងកាកសំណល់រឹងនៅកម្ពុជា ហើយបានចូលរួមនៅក្នុងសកម្មភាពស្រាវជ្រាវជាច្រើនក្នុងវិស័យនេះ៖ www.comped-cam.org។

## ឯកសារគន្លិទ្ទេសនិងឯកសារច្បាប់

សារាចរអន្តរក្រសួងស្ដីពីការអនុវត្តអនុក្រឹត្យលេខ១០៧០ លើការគ្រប់គ្រងកាកសំណល់រឹង ស.ឆ.ន. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន

សារាចរអន្តរក្រសួងលេខ១៤១១ ស.ឆ.ន. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការអនុវត្តមុខងារនៃការគ្រប់គ្រងសំរាម និងសំណល់រឹងនៅទីក្រុង

អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងសំរាមក្នុងទីក្រុង។

អនុក្រឹត្យលេខ២៨៦ អនក្រ.បកចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីនីតិវិធីក្នុងការរៀបចំ ការកែប្រែ និងការលុបចោលនៃដីកាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាខណ្ឌ។

សេចក្ដីណែនាំបច្ចេកទេសស្ដីពីការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងទីក្រុងនៃក្រសួងបរិស្ថានឆ្នាំ២០១៦

## សម្រាប់ព័ត៌មានបន្ថែមទាក់ទងទៅនឹងគម្រោង សូមទំនាក់ទំនង៖


### មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ២០៤ ផ្លូវលេខ៤៦២ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ +៨៥៥ ២៣ ៩៦៦ ១៧៦
ទូរសារលេខ ៖ +៨៥៥ ២៣ ២១៣ ៣៦៣
អ៊ីម៉ែល ៖ Office.PhnomPenh@kas.de
គេហទំព័រ ៖ www.kas.de/kambodscha
ហ្វេសប៊ុក ៖ www.facebook.com/kaskambodscha


## រៀបចំរបាយការណ៍ដោយ៖


### រ៉ូប៊ឺត ហ៉ែរ
សហការីស្រាវជ្រាវ
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា
ទូរស័ព្ទលេខ ៖ +៨៥៥ ២៣ ៩៦៦ ១៧៦
ទូរសារលេខ ៖ +៨៥៥ ២៣ ២១៣ ៣៦៣
អ៊ីម៉ែល ៖ Robert.Hoer@kas.de

### បណ្ឌិត ជោហ្គិន ស្តៅឌែល
ជំនាញការអន្តរជាតិលើផ្នែកគ្រប់គ្រងកាកសំណល់ និងអនាម័យ
ឡូធឹសខនសាល់ធីង
ទូរស័ព្ទលេខ ៖ +៤៩ ១៥១ ១៧២ ៦៤៣ ៧៣
ទូរសារលេខ ៖ +៤៩ ៣៦៤ ៣៤៤ ៤៩៩ ៣៣
អ៊ីម៉ែល ៖ juergen.staeudel@lotusconsulting.eu
គេហទំព័រ ៖ www.lotusconsulting.eu




# DEIKA ON SOLID WASTE MANAGEMENT (SWM) BATTAMBANG

## A Case of Participatory Legislative Drafting at Commune Level



COMPED

Konrad Adenauer Stiftung

LOTUS CONSULTING

Freedom, justice and solidarity are the basic principles underlying the work of the Konrad-Adenauer-Stiftung (KAS). The KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian-social, conservative and liberal traditions. His name is synonymous with the democratic reconstruction of Germany, the firm alignment of foreign policy with the trans-Atlantic community of values, the vision of a unified Europe and an orientation towards the social market economy. His intellectual heritage continues to serve both as our aim as well as our obligation today. In our European and international cooperation efforts, we work for people to be able to live self-determined lives in freedom and dignity. We make a contribution underpinned by values to helping Germany meet its growing responsibilities throughout the world.

